រឿង

# បីនាក់ស្វែងរកសំណាង

និពន្ធរឿង គូរគំនូរ  និងនិពន្ធកំរងកែវ
ដោយ    អ្នកស្រី កែវ ចន្ទ័បូរណ៍
ហៅ មិត្រ មេត្រី

P.O.Box 600279
Saint Paul, MN 55119
USA
khmervissal@yahoo.com
www.angkorwat.com

CHANBOKEO.COM
CHANBOKEO.COM

ខែមករា១៩៨១

រក្សាសិទ្ធិគ្រប់យ៉ាង

**សូមឧទ្ទិសចំពោះ**

- លោក មេង សួង សុវណ្ណធី ជាស្វាមី
- កុមារី **សុវណ្ណធី ធម្មិកា បារមីបុណ្យ** ជាបុត្រីទោល
- លោកឪពុក ប៊ុនថង និងអ្នកម្តាយ កែវយឿង
- លោកឪពុកក្មេក មេងសួង និងអ្នកម្តាយក្មេក កូវសារ៉ាន់
- លោក ខែម សារុំ និងភរិយា នៅរដ្ឋវ៉ាស៊ិងតុន សហរដ្ឋ អាមេរិក

CHANBOKEO.COM
CHANBOKEO.COM




អ្នកស្រី កែវ ចន្ទ័បូរណ៏
រដ្ឋមិនីសូតា សហរដ្ឋអាមេរិក
khmervissal@yahoo.com
www.angkorwat.com

# ស្នាដៃទាំងឡាយរបស់អ្នកនិពន្ធកែវចន្ទ័បូរណ៏

ប្រលោមលោកមនោសញ្ចេតនា :

១- រឿង និស្ស័យស្នេហ៍

២- រឿង ក្លិនផ្កាមារតី

៣- រឿង ផ្កាយវង្វេងមេឃ

៤- រឿង អប្សរា រាជធិតាមហានគរ

៥- រឿង នភាមណី

៦- រឿង ចេកមួយគុម្ព

៧- រឿង អនង្គលាភា

៨- រឿង លំអងផ្កាស្នេហ៍

៩- រឿង ភូមិបញ្ញាសម្ពន្ធ័

១០- រឿង បក្សីសួនសុបិន

១១- រឿង មធុរសបុប្ផ

១២- រឿង ម្លប់អសោក

១៣- រឿង រាជកុមារក្រៃពង្ស

១៤- រឿង កំប្រុកជុតិមន្តនិងរាជកុមារទល់ផ្អក

១៥- រឿង មេឃដ៏សក្តិសិទ្ធិ

ប្រលោមលោកមនោសញ្ចេតនាលាយកំប្លែង

១៦- រឿង បីនាក់ស្វែងរកសំណាង

១៧- រឿង លិខិតមរតកសំងាត់

សៀវភៅកំណាព្យ

១៩- គុណ និង សីលធម៌

២០- ឧទ្យានដួងចិត្ត

CHANBOKEO.COM
CHANBOKEO.COM

# វាចាអ្នកនិពន្ធ

រឿង  បីនាក់ស្វែងរកសំណាង បានត្រូវអ្នកនិពន្ធប្រតិស្ឋឡើងនៅខែមករា ១៩៨១ គ្រាដែលអ្នកនិពន្ធស្នាក់នៅកោះហ្គាឡង់ប្រទេសឥណ្ឌូនេស៊ី ។ កាលណោះ មាតុភូមិខ្មែរមិនទាន់មានតុល្យភាពពេញលេញនៅឡើយទេ ម្ល៉ោះហើយជីវិតរបស់ ប្រជាពលរដ្ឋខ្មែរភាគច្រើន នៅរងទុក្ខវិបត្តិផ្លូវចិត្តគួរអោយសង្វេគក្រៃលែង ទើប អ្នកនិពន្ធសំរេចចិត្តនិពន្ធរឿងនេះឡើង ក្នុងគោលបំណងធ្វើអោយអ្នកអានបាន ទទួលនូវការសប្បាយរីករាយក្នុងចិត្តមកវិញខ្លះៗ ដោយសារភាពកំប្លែងបន្តិចបន្តួច ដែលមាននៅក្នុងសាច់រឿង។  នៅខែមេសាឆ្នាំ២០០៤ អ្នកនិពន្ធក៏បានកែសំរួល សាច់រឿងនេះជាថ្មីដើម្បីអោយសមស្របទៅនឹងទេសកាលបច្ចុប្បន្នឡើងវិញហើយ បានបោះពុម្ពជាសៀវភៅឡើងដោយរោងពុម្ពកែវមណី សហរដ្ឋអាមេរិក។

ចំពោះកំហុសអក្ខរាវិរុទ្ធដែលកើតមានដោយអចេតនាទាំងឡាយនៅក្នុងសាច់ រឿង សូមប្រិយមិត្តមេត្តាជួយកែសំរួលអោយបានត្រឹមត្រូវតាមវេយ្យាករណ៏ខ្មែរ ប្រពៃផង ។ សូមប្រសិទ្ធិពរជ័យដល់ប្រិយមិត្តអ្នកអានទាំងអស់ សូមអោយបាន ជួបតែវឌ្ឍនសុខ និងសុវត្ថិភាពរាល់ទិវារាត្រី ។

CHANBOKEO.COM
CHANBOKEO.COM

អ្នកនិពន្ធ
អ្នកស្រី កែវ ចន្ទ័បូរណ៏
ខែមករា ១៩៨១

## សង្ខេបរឿង

# បីនាក់ស្វែងរកសំណាង

បុរសបីនាក់ជាមិត្តជិតដឹតនឹងគ្នាតាំងពីនៅកុមារមកម្ល៉េះ ។ ក្រោយមកគេក៏បានបែកគ្នា ទៅរស់នៅទីទៃរៀង១ខ្លួន ថៃដន្យស្រាប់តែបានមកជួបគ្នាវិញនៅពេលពួកគេចូលមកស្វែង រកភព្វ័សំណាងថ្មីសំរាប់ជីវិត ។ បុរសទីមួយឈ្មោះភោគ មានភរិយាឈ្មោះនាងប្រមូល ។ គេទាំងពីរធ្លាប់ឮល្បីថាជីវភាពអ្នកភ្នំពេញគេថ្កុំថ្កើងណាស់ ទើបគិតមានបំណងមកស្វែងរក មធ្យោបាយអោយក្លាយជាអ្នកមាននឹងគេដែរ ។ រីឯបុរសទីពីរឈ្មោះសំណាងមានរូបសង្ហារ អស្ចារ្យ ។ គេឮល្បីថា នៅភ្នំពេញមានការប្រលងប្រជែងរកបុរសរូបសង្ហា និងនារីរូបស្អាត ក៏គិតថា បើគេមានការធ្វើជាតារាបង្ហាញម៉ូដ គេប្រាកដជាបានជួបគូព្រេងជានារីសោភាក្នុង រង្វង់សង្គមស្រីស្រស់សោភាទាំងឡាយដែលដើរបង្ហាញម៉ូដណាមួយមិនខាន ។ រីឯបុរសទីបី វិញឈ្មោះរាសី ជាមនុស្សក្រីក្រហើយឆោតល្ងង់ជាងគេក្នុងចំណោមទាំងបីនាក់ ។ បុរសនេះ បានសំរេចចិត្តមករស់ភ្នំពេញនេះ គឺត្រឹមតែរកការងារលៀងក្រពះពីមួយថ្ងៃទៅមួយថ្ងៃ ប៉ុណ្ណោះ មិនប្រាថ្នាធំធេងអ្វីធំធេង ដូចមិត្តទាំងពីរនាក់របស់ខ្លួនឡើយ ។

ក្រោយពីការអស់សង្ឃឹមនឹងរកមធ្យោបាយជួយខ្លួនឯងហើយ អ្នកទាំងបីក៏បែកប្រាជ្ញ ទៅរកលោកគ្រូហោរាទស្សទាយបំភ្លឺផ្លូវជីវិតរបស់គេ ។ ស្រាប់តែលោកគ្រូទស្សន៍អោយថា នៅថ្ងៃមួយភោគនឹងមានលាភធំកើតជាអ្នកមានអស្ចារ្យ ហើយមួយឆ្នាំក្រោយមកទៀត សំណាងក៏នឹងបានការប្រពន្ធមួយរូបដែរ តែនាងជានារីម្នាក់ដែលនាយមិនបានពេញចិត្តទាល់ តែសោះ ។ លោកគ្រូបានបន្ថែមទៀតថា នៅថ្ងៃផ្សំរដំណេករបស់សំណាងនោះទៀតសោត នាយរាសីនឹងត្រូវមានគ្រោះអស់ជីវិតដែរ ។ ពុទ្ធោអើយ! ឥលូវនេះ តើគេទាំងបីត្រូវដោះ ស្រាយយ៉ាងណា? តើគេត្រូវជឿតាមលោកគ្រូហោរឬក៏ប្រឆាំងបែបណាទៅវិញ?

ដូច្នោះ សូមប្រិយមិត្តអញ្ជើញតាមដានសាច់រឿងរបស់យើងដូចតទៅ......

CHANBOKEO.COM
CHANBOKEO . COM

# វគ្គទីមួយ
# មធ្យោបាយធ្វើអត្តឃាត

នៅភូមិវត្តកំផែង ក្រុងបាត់ដំបង....

- សក្រវ៉ាទិផ្កាអង្គារដី អាសៀវលម៉ោងបី អាសៀវលម៉ោងបួន សក្រវ៉ាទិផ្កាត្រកួន អាសៀវលម៉ោង៤ អាសៀវលម៉ោងបី.... អាលឹម តក់ៗទឹកដក់ក្នុងថ្លុក អន្លក់ខ្ចីផ្ទាប់ជាមួយកប់ប៉ាហុក ស្រវ៉ាបាយញ៉ុក ភ្លេចកូនភ្លេចចៅ កាតាក់កាទឹងតាក់ កាតាក់កាទឹងទឹង...!!

CHANBOKEO.COM

- នែ៎ល្បងភោគ! យ៉ាងម៉េចហ្នឹង? ថ្ងៃនេះ មិនទៅរកលុយទេហ៎អី បានជាមកដេកច្រៀងអោយព្រងើយយ៉ាងហ្នឹង?
- ហៃយ៉ា! អូនប្រមូល ប្រពន្ធតែមួយប្រមាត់បងអើយ! ហេតុអី ក៏ប្ដីដេកច្រៀងលេងម៉ាងៃមិនបានដូច្នេះ? ដឹងទេហ៎ថាធ្វើការរកស៊ី វាហត់ណាស់... ប្ដីត្រូវការសំរាកខ្លះ?
- អឺ! ហើយចុះ បើមិនទៅរកស៊ីទេ តើយើងនឹងបានស្អីទិញអង្ករ ច្រកឆ្នាំងទៅហ្អ៉ាស តាប៉ិ?
- យឺអើ! ដេកតែស៊ីហើយ នៅឆ្លៀតត្រួតទៀត? រកតែសំរាកម៉ាងៃ ក៏មិនបានដែររឺយ!
- តែបើល្បងភោគឯងអាល័យតែទ្រមក់យ៉ាងនេះ តើថ្ងៃណានឹង កើតជាអ្នកមាននឹងគេទៅលោកអើយ?
- បើត្រូវមានវាមានហើយ មិនបាច់ខំទេ ណ៎អូនប្រមូល!
- កំជិលមែនតែម្ដង! ស្ដាយណាស់ដែលម៉ែឪលើកឱ្យមានប្ដី ប៉ះចំ លោកប្ដីមហាសំណល់ផ្អក...! ហ៊ឺ!
- អីយ៉ា! យាយប៉ិ! គ្នាខំរកចង់ងាប់ ថាឱ្យគ្នាសុទ្ធតែសំណល់ផ្អក... រួចចុះយាយប៉ិឯងវិញនោះ ដេកស៊ីៗ ឡើងមូលកំប៉ោង ដូចកំពឹងដូង តើគួរអោយខ្ញុំគិតម៉េចទៅវិញ?
- យ៉ស៎! ធ្វើប្ដីគេហើយចិញ្ចឹមតែប្រពន្ធមួយមិនរស់... ទៅបោក ក្បាលនឹងខ្នើយ អោយងាប់ម៉ាយប់ទៀតទៅលោកអើយ!
- អើ!ៗ បងស្លាប់ទៅម៉ាយប់... ធ្មប់វាមកយាមយំ... ដល់ស្លាប់ ម៉ាអាទិត្យធំ អូនឯងច្បាស់ជាដេកយំ សុំបងទៅតាមដែរហើយ... បើមិនជឿ....
- យីអើ! តាប៉ិសំគម បួមប្រេងមិនដល់ និយាយមានកិច្ច មានកល តិចថែមម៉ាដៃ ក្ស័យជីវ៉ា មែនទែនអាល្អូវ...!

- អ៊ូយ!ថាតែមាត់មិនបានទេហ្អី?   ម៉េចចាំលេងដៃជើងហើយថែម

ល្បោយទៀតយ៉ាងនេះ? ខ្លាចហើយ! លោកអើយ! ប្រពន្ធគ្រប ឆ្នាំងលក្ស័ ជើងធាក់ ដៃតប់ សន្លប់អស់ថៃ...

- នែ៎ឈប់ភ្លាម! ល្បងភោគ! កុំរត់ទៅណា៎! ខ្ញុំថាអោយឈប់!... ហ៊ានលេងសំដីជាមួយខ្ញុំឡូយណាស់តើហ៎ ថ្ងៃនេះ!...

កុំអាលរត់! នៅស៊ីសង គ្នាបន្តិចសិនមើស៍!



.O.COM

- ហៃយ៉ា! បើមិនរត់ មានតែភ្លើ...   នរណាគេសុខចិត្តនៅស្ងៀម ម៉ាកន្លែងអោយប្រពន្ធវ៉ៃ នោះ?.... ពុទ្ធោ!

- អុឺ! បើរត់មែន... រត់អោយលឿនៗទៅ... តែបើសិនជា ដួលវិញ... កុំក្រោកអោយសោះ ឮហើយនៅ?

តែបើហ៊ានតែ ក្រោកវិញ... ប្រយត្ន័ខ្ញុំ ថែមទាំងដើមទាំងការអោយទៀតណា៎!

នាងប្រមូលលីដងរែកដេញវាយនាយភោគជាប្តីហុយដីកាត់ភូមិ ផ្អើលអស់មាន់ទាទាំងក្រោល ស្រែកកេបកាបៗ

ស្តាប់អីលែង ឮតែម្តង។

មួយស្របក់ក្រោយមក ភោគក៏មកដល់ចុងស្ពានដែក ផ្លូវរទេះ ភ្លើង ចន្លោះវត្តសំពៅនិងវត្តកណ្ដឹង។ នាយដាក់ខ្លួនអង្គុយលើស្ពាន សំលឹងទឹក ស្ទឹងសង្កែដែលកំពុងហូរខ្ជួលខ្ជាញ់.... ធ្វើទឹកមុខហាក់ដូចជាកំពុងធុញថប់នឹងជីវិតរបស់ខ្លួនក្រៃលែង....

- ពុទ្ធោអើយ! នៅទំនេរមិននៅ ទៅការប្រពន្ធ ស្មានថា ចំណេញអោយគេមកបំរើយើង ដាំបាយដាំទឹកស៊ី... គ្រាន់នឹងយើង បានទំនេរខ្លួនខ្លះៗ តែមិននឹកសោះថា ដល់បានគេហើយ យើងបែរ ជាត្រូវដាំបាយដាំទឹក ធ្វើការផ្ទះអោយគេទៅវិញថែមទៀតសោះ។ យ៉ាប់មែន! មិនតែប៉ុណ្ណឹងទេ ថែមទាំងមានគេមកត្រួតត្រាជីវិតយើងនេះពីមុខពីក្រោយ ហាក់ដូចយើងនេះ ជាមនុស្សជាប់ទោស ជាប់ខ្នោះ គ្មានសេរីភាពអ្វីបន្តិចទេ លោកអើយ! យ៉ាប់មែន! ចង់តែស្លាប់ ស្លាប់! ស្លាប់! ទេខ្ញុំ!...

វំពេចនោះ ស្រាប់តែនាយភោគឮសូរសំលេងកូកហៅ :

CHANBOKEO.COM

- ល្បែងភោគ...! អង្គុយធ្វើអីហ្នឹង នៅលើស្ពាន... ចង់លោត ហែលទឹកលេងមែនទេហ៎?
- អ៊ូ! សំណាងតើហ៏! សុខសប្បាយជាទេហ៎? ឥលូវឯងដូចជា សង្ហារដល់ហើយហ្ន៎!!

(នាយភោគក្រលេកបែរមកឃើញហើយ ឧទានឡើង)

- ហៃសៗ! ខ្ញុំសុខ តែអត់សប្បាយទេ។
- ហ្អ៎ក! មិនបានអត់សប្បាយឥចឹង?
- ព្រោះអត់ប្រពន្ធនោះអីល្បែង!
- ហ្អើយ! ម៉ាអាប្រពន្ធហ្នឹង ទៅចង់បានយកមកធ្វើស្អី?... នាំតែ ស្លាក់កទេ។ មើលនែ៎ក! ដូចជារូបខ្ញុំនេះជាដើម...
- អូហ៏! អញ្ចឹងតើហ៏បានជាល្បែងមកសំកុកនៅទីនេះ ដើម្បីគេចមុខ ពីគាត់មកមែនទេហ៎?
- មិនត្រឹមតែរត់គេចមកទេ... គឺថែមទាំងមកអង្គុយគិតថា បើខ្ញុំ ចង់ស្លាប់វិញ តើខ្ញុំត្រូវរកមធ្យោបាយសំលាប់ខ្លួនយ៉ាងម៉េច... គ្រាន់ អោយវាងាយស្រួលងាប់...
- ហើយល្បែងគិតចេញខ្លះហើយនៅ?
- ចេញហើយ...
- រួចចុះម៉េចក៏មិនអនុវត្តន៏ទៅ? ចាំខ្ញុំជួយធ្វើជាសាក្សីកត់ត្រាហេតុ ការណ៏ ទុកជាប្រវត្តិសាស្ត្រ យកទៅជំរាបប្រពន្ធល្បែងវិញ។
- តែ.... ខ្ញុំធ្វើវាមិនទាន់កើត!!
- ម៉េចបានមិនកើត? បើពិតជាប្ដេជ្ញាចង់ស្លាប់ពិតមែន ហេតុអី ក៏ចាំរួញរាផង ហ្អ៎សល្បែង?

CHANBOKEO.COM

- មកពីគ្នាគិតចេញច្រើនមុខ ច្រើនមធ្យោបាយពេក ទើបមិន ដឹងថា ត្រូវជ្រើសរើសយកអាមួយណាវាល្អជាងគេ...

- ចុមយក្ស! ហើយម៉េចបានជាច្រើនមុខម្ល៉េះល្បង?

- យីអើ! បើយើងចង់សំលាប់ខ្លួនពិតមែននោះ យើងត្រូវតែខំរក មធ្យោបាយណាមួយ ដែលមិនអោយធ្វើយើងឱ្យវេទនា ប្រកាច់ ប្រកិនយូរពេក មុននឹងងាប់នោះអី ។

- អីយ៉ា!.......ដល់ល្បងនិយាយអញ្ចឹងទៅ ដូចជាពិរោះត្រចៀកខ្ញុំ ណាស់ ។ មើល៍ល្បង! ចែកខ្ញុំដឹងខ្លះមើល៍ ថាតើល្បងគិតចេញ ឱបាយទាំងអំបាលម៉ាននោះ វាយ៉ាងម៉េចខ្លះ? ចាំខ្ញុំជួយគិតគូរថា តើបងគួរតែជ្រើសរើសផ្លូវមួយណាសមជាងគេ ។

- អើហ៎! បើតចឹងចាំស្ដាប់ណ៎...

- បាទ!

CHANBOKEO.COM

- មធ្យោបាយទីមួយ ខ្ញុំគិតថា បើខ្ញុំគិតលោតទំលាក់ទឹកស្ទឹងហើយ លង់ងាប់នោះ ខ្ញុំនឹងត្រូវផឹកទឹកហើមពោះស្ដឹង ហើយច្រមុកទឹក ត្រដេវត្រដរ ខ្ញែ១ៗក្នុងទឹកតែម្នាក់ឯង ទំរាំដាច់ខ្យល់ស្លាប់ទៅ ។ ដល់ងាប់ទៅហើយ ហ្វូងត្រីច្បាស់ជាមកចឹកខ្ញុំស៊ីពីមុខពីក្រោយ របកស្បែក រលាត់កញ្ជែតកញ្ជួតអស់ ដល់ជាតិក្រោយកើតមក ខ្ញុំក៏ ក្លាយជាមនុស្សមានស្បែកអុជៗ ហើយមានសំលាកដាង ពពាល ពាសពេញខ្លួន... ពុទ្ធោ! ស្ដាយខ្លួនណាស់រ៉ើយ! ជាពិសេស បើត្រីវា ច្រលំចឹកភ្នែកស៊ីអស់ ដល់ជាតិក្រោយកើតមកអត់ភ្នែកវិញ តើ អោយខ្ញុំគិតយ៉ាងណា?

- អីយ៉ា! មែនហើយល្បង! ខ្ញុំគិតថាអាបែបមួយនេះ ដូចជាមិន សូវស្រួលទេ ។ អញ្ចឹង! សាកល្បងអាមធ្យោបាយទីពីរមើល៍ថាតើវា យ៉ាងម៉េចវិញ?

- អាម៉ូដទីពីរហ្នឹងគឺថា.... បើខ្ញុំឡើងទៅលើភ្នំ ហើយលោត ទំលាក់ខ្លួនចុះមកដី...

- ពុទ្ធោ! លោតពីលើភ្នំ? សាហាវណាស់តើហ៎ ដូចក្នុងកុនចិនអញ្ចឹង តែក៏ដូចជាស្លាប់លឿនដែរ បុំាងក្នុក តែលេវ! មិនបាច់តវ៉ាច្រើន ។ ខ្ញុំថា អាម៉ូដមួយនេះចំប្លង់ហើយ ។

- អត់ទេវើយ! អាមួយនេះក៏វេទនាដែរ ។

- ម៉េចអញ្ចឹងទៅវិញល្បង?

- សំណាងឯងគិតទៅមើល ។ ពេលគ្នាលោតចុះមកពីកំពូលភ្នំ កំពុង បង្ហើរខ្លួនកណ្ដាលអាកាស រួចបើហ្វូងក្អែកវាឃើញ នោះវានឹងខឹង ថាខ្ញុំនេះហោះប្រណាំងប្រជែងជាមួយវា ដែលជាសត្វស្លាបលើ អាកាសនោះស្រាប់ វានឹងខ្លាចបាក់មុខ ហើយក៏ដេញតាមប្រចឹក អោយយើងឱ្យវេទនាតាមផ្លូវមិនទាន់ធ្លាក់ដល់ដី... ពេលនោះ តើ

យើងត្រូវតដៃវាយ៉ាងណាវិញ មុននឹងខ្ញុំធ្លាក់ងាប់ទៅ? ប៉ុន្តែ លុះ ធ្លាក់ក្អុកមកដល់ដីហើយ ខ្លួនខ្ញុំនឹងសំប៉ែតបាក់ឆ្អឹង បាក់ឆ្អែង ទន់ល្វិកល្វក់ ។ លុះដល់ទៅចាប់ជាតិក្រោយ តិចលោកើតជាចេកទុំ ដែលគេសង្កត់ចៀនលក់ មិនរីវរធំតែម្តងទៅ ហើយទេហ៎....?

- យី! មែនហើយល្បង! ដល់គិតវែងឆ្ងាយតចឹងទៅ អាក្បួន លោតទំលាក់ពីលើភ្នំហ្នឹង ដូចជាមិនសូវឡូយសោះ ។ បើដូច្នេះ ល្បងដាក់អាម៉ូដទី៣ សាកលមើល៍ ក្រែងលោគ្រាន់បើជាងអាម៉ូដ ទីមួយនិងទីពីរ ។

- អ៊ើ! ចាំជួយស្តាប់ណា៎! ថាអាម៉ូដទី៣ ទៅរួចឬក៏អត់ ។

- ល្បងឆាប់និយាយមោ៎ លឿនឡើង!

- គឺថា.. បើអោយខ្ញុំឡើងចងកលើដើមឈើ រួចសំលាប់ខ្លួនវិញនោះ រូបខ្ញុំនឹងងាប់លៀនអណ្តាតតាឡៃតៃ ចេញមកក្រៅ ។ លុះដល់ជាតិ ក្រោយកើតមកម្តងទៀត តិចលោខ្ញុំកើតជាឆ្កែដើរលៀនអណ្តាត បង្ហៀរទឹកមាត់តាមផ្លូវសាធារណៈទៅ? ហើយពេលណាអ្នកស្រុក រាល់គ្នាក្រលេកឃើញខ្ញុំភ្លាម គេក៏ហៅនាំគ្នាហៅខ្ញុំថា " អាឆ្កែៗ... អណ្តាតលៀនថ្លៃ ព្រោះតែវីវាកាច់....អ៊ូយ! លើកនេះ ស្រេចតែ ម្តងហើយខ្ញុំ!

- ទេវតាអើយ! បីម៉ូដរួចហើយ ដូចជាវេទនាទាំងអស់តែម្តង គ្មាន មួយមុខណា គួរអោយបេតីចាប់អារម្មណ៍អ្វីបន្តិចសោះ ។

- មែនហើយ! អញ្ចឹងហើយបានជាខ្ញុំមិនដាច់ចិត្តធ្វើអត្តឃាដ នោះអី ។

- ហើយចុះល្បងឯងមានគិតចេញអាម៉ូដទីបួនហើយឬនៅ?

- នៅទេ... កំពុងតែគិតនៅឡើយ ។

- អញ្ចឹង... ខ្ញុំមានអាម៉ូដថ្មីមួយទៀត ។

- ម៉ូដអីទៅ..? មើល៍ និយាយចែកខ្ញុំស្តាប់ផង ក្រែងជាម៉ូដអស្ចារ្យ គួរអោយខ្ញុំអនុវត្តន៍បានជោគជ័យ...

- គឺល្បងសាកផឹកថ្នាំកណ្តុរហើយដេកងាប់វិញម្តងមើល៎ ដូចជា ស្រួលជាង ព្រោះងាប់ដេកលក់ វាមិនវេទនាផង ។

- ចុម!.. នរណាថា អាម៉ូដលេបថ្នាំកណ្តុរហ្នឹងវាដេកងាប់ស្រួលនោះ ព្រះអើយ?

- អូហ៎! ហេតុអ្វីទៅដែលថាមិនស្រួល ហ្អ៎សល្បង?

- គឺថា បើខ្ញុំផឹកថ្នាំកណ្តុរទៅរកដេកងាប់វិញ... នោះយើងនឹងបែក

CHANBOKEO.COM
CHANBOKEO.COM

ពពុះមាត់ខ្សុរប្រកាច់តែរ៉ៃ ស្រលៀងស្រលេវភ្នែក កាច់ដៃ កាច់ ជើង ក្រងិងក្រងង់ មុននឹងស្លាប់។

លុះស្លាប់ហើយទៅចាប់ជាតិជាថ្មី ស្រាប់តែកើតជាមនុស្សមានរោគប្រគ្រីវ កាច់ដៃកាច់ជើង ទាញ មាត់វៀច១

ភ្នែកស្រលេវ ហើយបែកពពុះមាត់ស្កុល១ ព្រឹកល្ងាច១ ហៃយ៉ា! គ្នាមិនរកស៊ីចូលទេរ៉ឺយ! ខ្លាចស្រីវត់អស់ លែងអោយ

យើងញ៉ៃអាលីងសូន្យសុង....

- យី! មែនហើយ! ដល់ល្បងពិចារណាវែងឆ្ងាយអញ្ចឹងទៅ ខ្ញុំក៏ គិតថា អាម៉ូដហ្នឹងក៏យ៉ាប់ ដៀវតែខ្ទូចទេ ល្បងអើយ។

- ហ៊ឺ! ពិបាកចិត្តណាស់ ចង់រស់ក៏យ៉ាក... ចង់ងាប់ក៏ពិបាក.... ទៅ ផ្លូវណាទៀតទៅនាយភោគអើយ..!! នែ៎ សំណាង!

ឯងមានទឹក ឃើញម៉ាម៉ូដ អីផ្សេងទៀតទេហ៎?

- ថីក៏មិនឃើញ!

- ម៉ូដអីទៅ និយាយមកមើស៍!

- គឺដេកលើស្ពានរទេះភ្លើងនេះ អោយរទេះភ្លើងវាបរកិន ជាការ ស្រេច!

- អុំញ! មិនលែងចូលទេ! អាម៉ូដមួយនេះ ច្បាស់ជាពិបាកចាប់ កំណើតណាស់!

- ហេតុអីទៅល្បង?

- ព្រោះថា បើដេកអោយរទេះភ្លើងវាកិនទៅ ខ្លួនយើងនឹងដាច់ ច្រើនកំណាត់រប៉ាត់រប៉ាយពេញដី...

- អែយួយ! វេទនាមែន!

- លុះដល់ទៅចាប់ជាតថ្មី វីវរ អាបំណែកអស់ហ្នឹង វាទៅចាប់ជាតិ វង្វេងគ្នា ខុសទីកន្លែង ខុសពេលវេលាគ្នា ដូចជា

ដៃចាប់កំណើត មុនជើង ជើងចាប់កំណើតមុនក្បាល ហើយក្បាលចាប់កំណើតមុន ខ្លួន

ទំរាំរកបំណែកមកផ្គុំគ្នាគ្រប់ចំនួននោះ តើត្រូវការពេលប៉ុន្មានឆ្នាំ ប៉ុន្មានជាតិទៅ?

- អូហ៎! មែនតើហ៎! ភ្លេចគិតអោយឈឹងទៅ...

- ហើយចុះបើអាចំណែកខ្លះ វាភ្លេចមកចាប់កំណើតវិញ នោះយើង មិនវិតតែយ៉ាប់ពុទ្ធោហើយទេហ៎ហ្អឺ?

អាម៉ូដមួយនេះ ដាច់ខាត គ្នា មិនលេង ជាមួយទេ សំណាងអើយ!

- អញ្ចឹង! ខ្ញុំក៏ទាល់ប្រាជ្ញដែរហើយល្បង។ មើលទៅ ល្បងត្រូវទៅ ផ្ទះវិញ ដេកគិតជាថ្មីតទៅទៀតហើយ។

- ហ៊ឺ!...... ទៅផ្ទះគិតអីចេញទៅ? គិតកាលណា ចេញតែមុខយាយ

ឡូឡា ឈ្មោះប្រមូលតែមួយប៉ុណ្ណឹង!

- បើល្បងគិតមិនចេញ ល្បងនៅរស់ម៉ាសន្ទុះសិនទៅ ចាំដល់នឹក ចេញម៉ូដថ្មីទៀត ចាំល្បងមករកខ្ញុំពិគ្រោះគ្នាចុះ។

CHANBOKEO.COM

- មែនហើយវ៉ី! កើតទុក្ខរឿងប្រពន្ធជាន់ក ដូចជាមិនពិបាកដូចកើត ទុក្ខ ដេករកទឹកអាម៉ូដសំលាប់ខ្លួនដែរ ។ អញ្ចឹង! ខ្ញុំគិតទៅផ្ទះវិញ សិនហើយ ។ ថ្ងៃក្រោយ យើងជួបគ្នាទៀតណា៎!

- បា៎ទ! អញ្ជើញទៅរស់ម្តងទៀត អោយសុខសប្បាយណា៎ល្បង ។

- បាទ! អូហ៎នែ៎ គ្នាភ្លេចសួរមួយ!

- រឿងអីទៅល្បង?

- បើខ្ញុំចង់រកសំណាងឯង តើអោយខ្ញុំទៅរកឯណាឃើញ?

- ហ៎ែសៗ ទូកជីវិតរបស់ខ្ញុំក៏មិនទាន់មានគោលដៅជាក់លាក់ដែរ... កំពុង តែស្វែងរកកំពង់ចត ។ ឥលូវនេះ ខ្ញុំមិនទាន់មានការធ្វើទេ ហើយក៏មិនទាន់មានគូស្រករទៀត មិនដឹងថ្ងៃណាលាភមកដល់ សោះ ។ តែណ្ហើយចុះ! បើខ្ញុំទំនេរ ចាំខ្ញុំទៅលេងល្បង និងប្រពន្ធនៅ ឯភូមិវត្តកំផែងវិញ ។

- អឺ! បើឥចឹង គ្នាលាទៅសិនហើយណា៎ គិតទៅរកដាំបាយជូន អ្នកស្រីចៅហ្វាយសិន ខ្លាចគេញ៉ាំងស្លឹកត្រចៀកដាច់ទងសាថ្មី ។

- បាទៗ! អញ្ជើញល្បង! ថ្ងៃក្រោយជួបគ្នាទៀត!

ថាហើយ សំណាងក៏ដើរបកក្រោយទៅវិញ ទុកអោយនាយភោគនៅឈរអេះក្បាលតែម្នាក់ឯង ។ មួយស្របក់ក្រោយមក នាយភោគក៏ដើរត្រលប់ទៅផ្ទះវិញដោយដំណើរតយង៉ាង៉យ...

រស់ក៏មិនគាប់ ងាប់ក៏មិនគួរ

១. នឹកឡើងពិបាកក្រៃ មិនចង់ក្សិណក្ស័យ ចង់តែរស់នៅ
មានប្រពន្ធមួយ រូបស្អាតពេកកូវ គន់មើលយូរទៅ មូលដូចល្ពៅបបរខ៊ិះដូង ។

២. ងាប់ទៅរស់នៅក៏ល្អ ប្រពន្ធជាន់ក បោះចូលទឹកប្រូង
ផឹកទឹកស៊ីង រហូតដល់ថ្លាល់វាខូង ភ្នែកវិញក៏រូង ពេទ្យមើលលែងជា ។

៣. នឹកឡើងព្រួយចិត្តសាថ្មី មិនប្តូរសង្ស័យ មិនចង់មរណា
ប្រពន្ធដកស្លាបថែមខ្វីដាក់ឆា ក៏ប្រសើរអស្ចារ្យ ជាងងាប់មុនអាយ៉ូស ។

៤. រស់មិនគាប់ងាប់មិនគួរ បើប្រពន្ធហៅសួរ ផាយហុយដីសុះ
បើព្រះលោកភ្លេចយាងមកប្រោស សុខចិត្តនៅត្រេះត្រុះ ជិតម៉ែប្រពន្ធចុះអើយ ។

0000000000000000000

000

0

# វគ្គទីពីរ

## អ្នករកស៊ីបីមុំ

ថ្ងៃស្អែកឡើង..

- អឺយ! តាប៉ុភោគ! ងើបឡើង! លឿន!

- ហ្អាស! ស្រែកថីហ្នឹង អូនប្រមូល? ភ្លើងឆេះផ្ទះហ្អែស?

- យីអើ! ចាំតែភ្លើងឆេះផ្ទះ ទើបបានងើបពីដេកឬក៏យ៉ាងណាហ្នឹង? នែ៎! ថ្ងៃរសៀលណាស់ហើយ! ឆាប់ងើបចេញរកស៊ីមើល៍!

- ហ៊ឺ! ដូចជានៅថ្ងៃយ៉ាងនេះ អ្នកណាគេទិញសាច់គោអាំងយើង លក់ទៅ? ចាំដល់ល្ងាចបន្តិចសិនចាំចេញទៅអាំងសាច់គេលក់... ហើយចុះអូនឯង មានឈូសល្ហុងធ្វើជ្រក់ហើយនៅ?

- យីតាប៉ុ! តាឯងទៅលក់សាច់គោអាំង មិនមែនទៅលក់ជ្រក់ ល្ហុងទេ...

- អូហ៎! បងពិតជាមិនដឹងសោះ ថា អាម៉ូដលក់សាច់គោអាំង ដោតចង្កាក់ សម័យអាលូវនេះ គេមិនមានដាក់ជ្រក់ល្ហុង? អស្ចារ្យមែន! សម័យជឿនលឿនគេកាត់បន្ថយខ្ទេចខ្ទីរអស់អញ្ចឹងហ្អ៎?

- មិនមែនមកពីសម័យជឿនលឿនទេ តែគឺជាសម័យសន្សំសំចៃ មិនរាយមាយ មិនខ្ជះខ្ជាយផ្ដេសផ្ដាសនោះអី។

- អឺ! អោយតែរបៀបហ្នឹងចុះ! រកស៊ីធូរធារឆាប់មិនខាន។

- នែ៎! កុំរអ៊ូច្រើន! ប្រញាប់ចេញទៅរៀបតវ៉ាន់ទៅ អាលចេញ ទៅលក់។

- អីយ៉ា! ថ្ងៃនេះ យាយប៉ុចេញទៅលក់ជាមួយបងដែរហ្អែស?

- អ្នកណាថា? គឺតាប៉ុឯងហ្នឹងណា៎ អ្នកទៅលក់! រឿងស្រី១ អ្នកជា ប្ដីត្រូវតែថ្នមគេខ្លះ អោយគេធ្វើការនឿយខ្ចូចសាច់ខ្ចូចឈាមគេ អស់ហើយ!

- ពុទ្ធោ! ហើយចុះបើប្រើប្ដីយ៉ាងហ្នឹង មិនខ្លាចប្ដីខ្ចូចសាច់ខ្ចូចឈាម ដែរទេឬអីហ្អាស អូនប្រមូល?

CHANBOKEO.COM
CHANBOKEO.COM

- តវ៉ាច្រើននេះច្រើន តិចចូលដើមអាល្ងវ!

- អឺៗ ទៅហើយ... កុំលេងយារដៃអញ្ចឹង! តែបើយារដៃហើយ ក៏ទះទៅ កុំអោយខកដៃ... តែកុំទះខ្ញុំ ឮហើយនៅ?

នាយភោគរត់ត្របាញ់ជើងទៅរៀបធុង រៀបចាន រៀបធ្យូង រៀបអុស រុញធុងអាំងសំដៅផ្សារណាត់ភ្លាមឥតបង្អង់។ នៅទីនោះ នាយបង្កាត់ធ្យូងដាក់សាច់គោអាំងលក់ ស្រាប់តែប្រទះបុរសម្នាក់ កំពុងរែកបំពង់ទឹកត្នោតមួយអំរែកយ៉ាងធ្ងន់មកដល់។ គាត់ក៏ស្រែក ហៅឡើងថា :

- អឺ! រាសី.... អែយ៉ា! ថ្ងៃនេះ មានរែកទឹកត្នោតមកលក់ ផងហ្អែស?

- អូហ៍ ល្បងភោគ! ថ្ងៃនេះទឹកត្នោតវាសំបូរ ទើបរែកយកមក លក់ ឡើងចង់បាក់ស្មាទៅហើយ។

- អីយ៉ា! ហើយអាទឹកត្នោតហ្នឹងជូរឬក៏ផ្អែម?

- អាផ្អែមលក់បានអោយតែស្រីៗទេ! ទំរាំនឹងលក់ដាច់ម្ដងៗ ល្បង អើយ! ស្រីៗគេ តថ្លៃដល់សូរហើយ មិនដែលរួចថ្លៃរែកម្ដងណាទេ ទើបថ្ងៃនេះ ខ្ញុំបែកប្រាជ្ញសាកលក់ទឹកត្នោតជូរម្ដង សង្ឃឹមថា ថ្ងៃនេះ ត្រលប់ទៅវិញ បានប្រាក់កំរៃខ្លះ។

- ហ៎សៗ! ធំក្លិនឈ្ងុយ យ៉ាងនេះ ដូចជាចង់សាកដល់ហើយខ្ញុំ... ទាស់តែវា អត់លុយទិញ លក់សាច់គោមិនទាន់ដាច់ម៉ាចាកាក់ផង។

- មិនអីទេ ល្បង! ទឹកត្នោតដល់ទៅជាងម្ភៃបំពង់ឯណោះ ចាំខ្ញុំទុកអោយមួយបំពង់ ពេលល្បងលក់បានលុយ ចាំមកយកទៅ។

- អើអញ្ចឹង រាសីឯងកុំទៅលក់ឯណាឆ្ងាយអី។ ដាក់លក់នៅម្ដុំៗ នេះហើយ ដល់គ្នាមានលុយទិញ ស្រួលកូកហៅរកឆាប់ឮផង ត្បិតគ្នាដើរចោលរានលក់សាច់គោអាំងមិនបានទេ គ្មានអ្នកនៅ ជួយមើល ខ្លាចចោរវាលួចអស់។

- បាទ! អញ្ចឹងក៏បាន។

រំពេចនោះ ស្រាប់តែបុរសទីបីមកដល់ដែរ ដោយមានរុញរទេះ ដាក់ទូកញ្ចាក់លក់ស្វាយត្រាំ កន្ទួតត្រាំ និង ម្កាក់ត្រាំ។ ជួននាយភោគ ដាក់ភ្នែក ក្រលេកទៅចំឃើញភ្លាមក៏លាន់មាត់វ៉ាងឡើងខ្លាំងៗថា :

- ហៃយ៉ា! ប្អូនសំណាង! ថ្ងៃនេះក៏ចេញរកស៊ីនឹងគេដែរហ្ន៎?

មែនហើយ! នោះគឺជាបុរសសង្ហារឈ្មោះសំណាង ដែលបានជួប នាយភោគឯស្ពានរទេះភ្លើង ជិតវត្តសំពៅកាលពីថ្ងៃមុន។ គ្រាន់តែ ក្រលេកឃើញនាយភោគនិង រាសីភ្លាម សំណាងក៏លាន់មាត់ដែរ :

CHANBOKEO.COM
CHANBOKEO .COM

- ហ៉ែសៗ!  ដើរលក់សន្ទុំលុយទៅភ្នំពេញណាល្បង! ហើយចុះ ល្បងទាំងពីរ
ឥលូវក៏ចេះរកស៊ីលក់ដូរអីៗហ្នឹងដូចគេដូចឯងដែរ តើហ៎ ! ស្មានថាមាន តែខ្ញុំទេ ដែលកែប្រែចិត្តគំនិតឈប់ខ្ជិលនោះ? ដឹងអីពេលនេះបែរជាបាន គ្នាដល់ទៅបីនាក់ គ្រប់មុំគ្រប់ជ្រុងល្មម ខ្មោចលែងហ៊ានលងហើយ ។

រាសីឮហើយក៏ឆ្លើយ :

- ខ្ញុំឯណាដែលខ្ជិល មិនរកស៊ីនោះ? ការពិត ចំពោះខ្ញុំ អារឿង រកស៊ីមួយ មិនចេះខ្ជិលទេ តែបើអារឿងរកទុក ទើបវាយ៉ាក ។

- ម៉ាច់ក្នុងអ៊ុច! ខ្ញុំវិញក៏អញ្ចឹងដែរ (នាយភោគបន្ទរ) រកស៊ី គឺមិន ចេះខ្ជិលសោះ.... តាំងពីដើមរៀងមក ។ ហើយចុះ សំណាងឯងមាន លក់ដាច់ខ្លះ ហើយឬនៅ តាំងពីរុញរទេះចេញពីផ្ទះមក?

- នៅទេ ល្បង! ខ្ញុំខំរុញសំដៅមាត់ស្ទឹងសង្កែ មកលក់មុំៗនេះ ត្បិតខ្ញុំឃើញនារីក្រមុំៗរូបស្អាតៗគេលក់ចំណីបង្អែម... សង្ឃឹមថា គេត្រូវការរបស់ជូរៗ លាងមាត់នោះអី ។  ម្យ៉ាងទៀត ខ្ញុំក៏បាន អង្គុយមើលមុខស្រីស្រស់ស្អាតទាំងឡាយនោះផង ។

- កុំទៅលួចមើលគេធ្វើអី! លួចមើលគេទៅ... តិចយូរៗទៅ ស្រលេវភ្នែក! (រាសីនិយាយ)

- អូហ៎ បើសំណាងលួចមើលគេស្រលេវភ្នែក លើកក្រោយសុំគេ មើលត្រង់ៗ ទៅ លែងប្រលេវហើយ (នាយភោគបន្ថែម)

- ហ៉ែសៗ! (រាសី) បើសុំមើលគេត្រង់ៗ ក៏ត្រូវមើលមុខមើល ក្រោយដែរណា! វីវរ តិចមានដំបងដេញកែង រត់មិនទាន់....

- អូហ៎ ! អត់ទេ ល្បងរាសីអើយ!   ខ្ញុំសុខចិត្តស្រលេវភ្នែកចុះ តែមិនសូវចង់តស៊ូនឹងដំបងដេញកែងនោះឡើយ (សំណាងតប)

ទាំងបីនាក់អង្គុយជជែកគ្នាបណ្ដើរលក់បណ្ដើរ... ។ នាយភោគ ធុំក្លិនទឹកត្នោតជូរជះភាយៗតាមខ្យល់ មកដាក់មុខនាយម្ដងៗ ក៏នឹកស្រេវទឹកមាត់ច្រោកៗ ។ រីឯនាយសំណាងនិង នាយរាសីវិញ កាលបើឃើញសាច់គោអាំងចោលក្លិនឈ្ងុយៗ ក្បែរចុងកន្ទួតត្រាំ ស្វាយត្រាំ ក៏ចេះតែលួចមើលភ្លៀកៗ មិនដាក់ភ្នែកដែរ រួចក៏នាំគ្នាលួចលេបទឹកមាត់ក្អឹកៗ តែមិនហ៊ានមាត់តែរៀងៗខ្លួន ។ មួយសន្ទុះ ធំក្រោយមក គេទាំងបីក៏នៅមិនទាន់ លក់ដាច់អ្វីមួយរៀលសោះ ក៏នាំគ្នាអង្គុយធ្វើមុខជូស្អុយប៉ែ ។ រំពេចនោះ ស្រាប់តែនាយភោគ ផ្ដើមវាចាមុនគេថា :

- យីអើ នាយរាសី! ទឹកត្នោតមួយបំពង់ថ្លៃប៉ុន្មានដែរ?

CHANBOKEO.COM

- អីយ៉ា! ល្បងភោគ! ចុះក្រែងអំបាញ់មិញល្បងថាអត់លុយទិញទេ ហើយម៉េចពេលនេះ
បានជាសួរតំលៃទឹកត្នោតឥចឹង?

- អ៊ើយ! គ្នាអត់លុយពិតមែន តែគ្នាគិតថា បើគ្នាយកសាច់គោអាំង ដូរនឹងទឹកត្នោតជូរ តើឯងសុខចិត្តដែរឬអី?

រាសីឮហើយ ក៏ហាក់ដូចជាកូរពោះលាន់គ្រូក១ ទឹកហៅរក សាច់គោអាំងភ្លាមដែរ ។
នាយយើងក៏ឆ្លើយយ៉ាងរហ័សថា :

- បាទ! ខ្ញុំបំរុងថានឹងសួរល្បងឯងអញ្ចឹងដែរ ។

រំពេចនោះស្រាប់តែសំណាងពោលឡើងថា :

- អីយ៉ាល្បងភោគ! ធ្វើយ៉ាងហ្នឹងដូចជាមិនយុត្តិធម៌សោះ ។

ភោគឮដូច្នោះក៏នឹកឆ្ងល់ :

- ហេតុអ្វីបានថា មិនយុត្តិធម៌? យើងដូរទៅដូរមកស្មើដើម តាម
ការយល់ព្រមរវាងយើងទាំងសងខាងទៅហើយ ម៉េចក៏ថាមិនត្រឹម ត្រូវទៅវិញ?

- ព្រោះអីល្បងឯងដូរតែទឹកត្នោតជូរ រួចមិនជួយដូរយកស្វាយត្រាំ កន្ទួតត្រាំរបស់ខ្ញុំទេហ៎? ដឹងទេហ៎ថាអាគ្រឿងអស់នេះ ក្លែមជា មួយទឹកត្នោតជូរ សាច់គោអាំងឆ្ងាញ់រកលខដាក់គ្មានទេណ៎ាល្បង!

នាយភោគនិងនាយរាសីសំលឹងមើលមុខគ្នាមួយភ្លែត ក៏ញញឹម ឡើង ហើយលាន់មាត់ព្រមគ្នាថា :

- យីអើ! យោបល់ល្អណាស់! ដូរមួយទៅ មួយម៉ោហ៎ ស្មើដើម មិនបាច់បង់ប្រាក់! ហើយយើងក៏បានបរិភោគ
តាមដែលយើង ប្រាថ្នាផង ។

បន្តិចមក នាយរាសីចាក់ទឹកត្នោតអោយនាយភោគដូរសាច់គោ អាំង ។ រីឯនាយភោគលើកចង្កាក់សាច់គោរអាំង ដូរយកកន្ទួតត្រាំ ស្វាយត្រាំពីនាយសំណាង ។ សំណាងក៏យកស្វាយត្រាំកន្ទួតត្រាំដូរទឹក ត្នោតជូរ ។ ទាំងបីនាក់ក៏អង្គុយដឹកង់ជាបីមុំ ដូរទៅដូរមក ហើយក៏ អង្គុយក្លែមព្រោកប្រាជ្ញ១ បែកពពុះមាត់ស្កុលតែរៀង១ខ្លួន ។ ដល់ អស់មួយសាហើយ ក៏នាំគ្នាដូរទំនិញទៅមកសាជាថ្មី ហើយវាតវង់ ព្រោកប្រាជ្ញបន្ត... ថ្ងៃលិចទៅហើយ... អ្នកទាំងបីនៅតែព្រោក ប្រាជ្ញមិនទាន់ចប់រឿងនៅឡើយ ។ សាច់គោអាំងក៏អស់ពីរានអាំង ទឹកត្នោតក៏អស់ពីបំពង់ រីស្វាយត្រាំកន្ទួតត្រាំក៏អស់ពីទូកញ្ចក់ដែរ តែ គេមិនខ្វល់ទេ ត្បិតម្នាក់១កំពុងទន់បបូរមាត់ លែងគិតពីអ្វីចេញ ហើយ ក្រៅតែពីជជែករឿងបែកប្រាជ្ញម្តង ។ ថ្ងៃនេះ គ្មាននរណា លក់បានប្រាក់មួយរៀលសោះឡើយ ត្បិតអាល័យតែរវល់ កិច្ចការ បីមុំរបស់គេមិនទាន់ចប់សេចក្តី ។ នាយភោគនិយាយទៅកាន់នាយ សំណាងមុនគេថា :

CHANBOKEO.COM

- មើល៍ សំណាង! ឯងមានរូបសង្ហារជាងគេ ក្នុងចំណោមយើង ទាំងបីនាក់ហើយឯងក៏នៅកំលោះទៀត ។ នេះបើឯងចេញទៅ ភ្នំពេញរកប្រលងក្នុងកម្មវិធីស្រីស្រស់ប្រុសសង្ហារនឹងគេ ប្រហែល ជាឯងបានជាប់ជាតួឯក បង្ហាញម៉ូដមិនខានឡើយ ។

- មែនឬល្បង? ខ្ញុំកំពុងតែស្រម័យថាចង់ធ្វើដូច្នោះដែរណា៎! គ្រាន់តែមិនដឹងថានឹងទៅភ្នំពេញតាមណា ហើយចូលប្រលងតាម ខ្សែរយៈណា ដើម្បីអោយបានចូលដល់គោលដៅនោះ ។ បើល្បងដឹង សូមជួយណែនាំខ្ញុំផង!

- អត់ទេ! គ្នាចេះតែថា១ទៅទេវ៉ឺយ! ការពិតគ្នាមិនដែលទៅ ភ្នំពេញម្តងណាសោះ ។ បើឯងសួរយើងពីភ្នំពេញនោះ មិនខុសពីសួរ ក្របីទេហ៎ ។

ភ្លាមនោះ រាសីធ្វើភ្នែកស្លឹសំលឹងនាយភោគរួចលាន់មាត់ថា :

- ហ្អ៎ក? ហើយចុះល្បងភោគកើតជាក្របីតាំងពីអង្កាល់ ម៉េចបាន ជាខ្ញុំអត់ដឹងសោះឥចឹង? (នាយរាសីសួរធ្វើមុខស្លឹ)

- ហៃយ៉ា! យើងមិនមែនក្របីទេវ៉ឺយនាយរាសី! គឺអ្នកសួរមិនដឹង ខ្យល់អីហ្នឹងតើហ៎ដែលជាក្របីនោះ ឯងដឹងទេហ៎? ហើយចុះនាយ រាសីឯងវិញ តើមានបំណងប្រាថ្នាធំដុំយ៉ាងណាដែរទៅហ្អ៎ស?

- ខ្ញុំថា អោយតែរស់ឆ្អែតមួយគៃ១ទៅ ខ្ញុំសប្បាយចិត្តណាស់ទៅ ហើយ! ចុះល្បងភោគឯងវិញនោះ?

- ខ្ញុំក៏គិតដូចតែរាសីឯងអញ្ចឹងដែរ...តែម៉ែប្រពន្ធគាត់មិនយល់ដូច គ្នាសោះ ។ ម៉ែ្១ គាត់ដេកស្រម័យឃើញលុយធ្លាក់ដុំ១ពីលើមេឃ មកលើដី ដើររើសអោយរពុយ... គ្នាពិបាកចិត្តណាស់ពេលនិយាយ ពីរឿងនេះម្តង១ ចង់តែស្លាប់ទៀតហើយ..

រំពេចនោះស្រាប់តែ...

- យើស! តាប៉ិភោគ! ចង់ងាប់ណាស់មែនទេហ៎? ថ្ងៃនេះប្រហែល ថ្ងៃចុងក្រោយហើយដែលតាប៉ិឯងដកដង្ហើម! មើស៏ ឯណាលុយលក់ សាច់គោអាំង? ឆាប់អោយភ្លាមមក៏!... ឆាប់ឡើងមើល៏!! នែ៎.... តាប៉ិភោគ..! ឯណា? លឿនឡើង... កុំអោយខ្ញុំ ក្តៅចិត្តទាន់...! តិចថាអត់មិនបានឥលូវហ្នឹង...

កាលបើក្រលេកមកឃើញប្រពន្ធភ្លាម ភោគក៏ភ្ញាក់ផ្អើលឡើងៈ

CHANBOKEO.COM



- ចុមយក្ស! ហេតុអីក៏លួចដើរចូលមកស្ងាត់ៗហ្នាស អូនប្រមូល?

នាយភោគបើកភ្នែកធំៗ ធ្វើរញៀរញ៉ូវ ដូចឃើញខ្មោចលងបេះ ដាក់។ នាងប្រមូលក៏ដើរចូលមកជិត ហើយសង្កមភ្នែកក្រហម ដាក់នាយភោគថែមទៀត ព្រមទាំងហុចដៃទារ :

- ឯណាលុយលក់សាច់គោ? ឆាប់អោយភ្លាមមក៏!

នាយភោគក្រោកឈរ ធ្វើអេះអុញៗ រួចក៏លើកដៃចង្អុលទៅ នាយរាសីហើយឆ្លើយតតាក់តតុបថា :

- លុយ... លក់សាច់គោ... អាំងនោះ... បងយកទៅសងថ្លៃ ទឹកត្នោតអស់ហើយ នេះ៎ ផ្ញើជាមួយ..... ម្នាក់នេះណា៎!

រាសីឃើញដូច្នោះក៏លើកដៃរាហើយគ្រវីក្បាលញាប់ដូចបង្ហួយ។ នាយប្រកែកទៅវិញថា :

- អូហ៏...អត់ទេហ៏ បងស្រីអើយ! ការពិតរឿងលុយហ្នឹង... ខ្ញុំបាន ហុចបន្តអោយល្បងខាងនេះសងថ្លៃស្វាយត្រាំកន្ទួតត្រាំអស់ហើយ។

រាសីថាផង ចាប់ដៃនាយភោគចង្អុលបំបែរទិសរកនាយសំណាង ផង។ ស្រាប់តែសំណាងបើកភ្នែកមូលក្លំ ឆ្លើយថា :

- លុយ...ហ្នឹង...វាមកដល់ខ្ញុំមែន... តែ... ខ្ញុំយកទៅអោយថ្លៃសាច់ គោអាំងរបស់ល្បងភោគវិញអស់ហើយតើហ៏!

- នែ៎! កុំចេះតែថា! គ្នាមិនទាន់បានទទួលទេវ៉ើយ! (នាយភោគ ឆ្លើយកាត់)

- ម៉េចក៏ថាអត់?...បើមិនជឿសួរនាយរាសីទៅមើល៍!! (សំណាង ប្រកែក)

ទាំងបីនាក់ចង្អុលដាក់គ្នា ទៅមក៏ៗ ចុះឡើងៗ ធ្វើអោយនាងប្រមូលវិលគ្រាប់ភ្នែក ដូចពិងប៉ុងបាញ់លេខឆ្នោតអញ្ចឹង។ ទ្រាំមិនបាន នាងប្រមូលក៏គំហកអោយទាំងបីនាក់ :

- នែ៎ បើរកអាលុយលក់សាច់គោអាំងហ្នឹងមិនឃើញមកវិញទេនោះ អាដងវែកមួយនេះវាសូមធ្វើការតាមរកជំនួសហើយ។

រាសីញ្ញាក្លាមក៏សំលឹងមុខនាងប្រមូល ឃើញនាងខមភ្នែកយ៉ាង ធំដាក់អ្នកទាំងបីព្រមទាំងធ្វើមុខមាំកាន់ដងវែកជាប់នឹងដៃ បំរុង ដើងការវាយលុកជាស្រេច ក៏ស្ទុះក្រោកក្រេះហើយឧទានឡើងថា :

- ខ្ញុំគិតថា ទោះជាខ្មោចលង ក៏មិនគួរអោយភ័យខ្លាច ស្មើនឹង ដងវែកដេញប្រផាស់ឆ្អឹងខ្នងដែរ... ខ្ញុំសូមលាទៅមុនសិនហើយ លោកអើយ...

រាសីកផាយរឹងបាតជើងសព្រាតហុយដីទ្រលោម។ លុះឃើញ រាសីផាយផាស់ក្រញាំចោលបំពង់ទឹកត្នោតជូរប៉ាត់រប៉ាយពេញផ្លូវ សំណាងក៏ស្ទុះងើបឡើងផាយតាមក្រោយដែរ :

- សូមទោសអ្នកបង! ខ្ញុំឈឺពោះ សុំខ្លួនទៅរកកន្លែងគួរសមសិន។

នាយភោគឃើញមិត្តរបស់ខ្លួនផាយអស់ ក៏នឹកព្រឺឆ្អងខ្នងខ្វាកៗតែម្តង។ នាយយើងមើលមុខមើលក្រោយចុះឡើងរួចហើយក៏ដាក់ មេប្រុយយ៉ាងលឿនស្លេវ មិនខ្ចីធ្វើមាត់អោយសញ្ញាម៉ាមាត់ជាមុន ឡើយ ទុកអោយនាងប្រមូលរត់តាមស្រែកហៅពីក្រោយឡូងៗ :

- នែ៎! តាប៉ុភោគ! ប្រញាប់រត់ទៅណា៎? នែ៎ មកជំរះបញ្ជីសិន! កុំរត់មើល៍...!

គួរអោយស្តាយ នាយភោគរត់បាត់ស្រមោលតាមពីក្រោយ នាយរាសី និងសំណាងបាត់ទៅហើយ។ មួយភ្លែតក្រោយមក នាយ ភោគរត់មកដល់ជាយខាងលិចផ្សារណាត់ ក៏ប្រទះនឹងមិត្តរបស់ខ្លួន ទាំងពីរនាក់កំពុងអង្គុយហត់ដកដង្ហើមគឃូស ទល់មុខគ្នានៅមុខ ហាងទំនិញមួយ ដែលមានមនុស្សច្រើនអ៊ូអរនៅឡើយ។ កាលបើបានជុំជើងបីមុំជុំគ្នាវិញហើយ គេទាំងបីនាក់ក៏ញញឹមដាក់គ្នាឡើង សាជាថ្មីយ៉ាងបំព្រង ហើយលាន់មាត់ព្រមគ្នា ថា :

- មិត្តចិត្តមួយថ្លើមបី បានរួចទុក្ខភ័យ មិនខ្ចីចូលផ្ទះ បំណាច់នឹង ក្រញាំផាស់ គិតដើរផ្តេសផ្តាស ម៉ាសន្ទុះទៀតសិន.... ហ៉ៃសហ៉ៃ!

CHANBOKEO.COM

ពួកគេក៏កៀកកក្ដាសើចកក្អេកទន់មាត់ទន់ក បាក់លោងទាំងបី នាក់នៅទីនោះទៅ ។

0000000000000

000

0

CHANBOKEO.COM

CHANBOKEO.COM

## វគ្គទី៣

## ហោរទាយឆុត

ក្លើទាំងបីនាក់បានកៀកកន្ទាបណ្ដើរ ដើរច្រៀងបណ្ដើរតាមផ្លូវៈ - រលឹមតក់ៗ ទឹកដក់ក្នុងចាន ស៊ីក្លូរៀបការជាមួយឡាន កើតកូន មកបាន... ជាអាទើងផ្លេះ.... (អាតេះភ្លើង)... កាតាក់កាទីងតាក់ កាតាក់កាទីងទីង! សក្រវាទិផ្កាក្រសាំង ប្រពន្ធមាត់ខ្លាំង ដាំបាយ ខ្លោច សក្រវាទិផ្កាក្រូចសើច ដាំបាយខ្លោចឱ្យប្រពន្ធមាត់ខ្លាំង...

ភ្លាមនោះ នាយភោគងាកបែរទៅម្ខាង ឃើញមនុស្សឈរវាត វង់នៅជុំវិញរានមួយដែលមានអុជចង្កៀងភ្លឺផ្លុងៗ ។ ភោគក៏លាន់ មាត់ភ្លាមឡើងថា :

- អីយ៉ា កនយើង! នៅកន្លែងនោះ គេមានចាក់អាប៉ោងហ្អ៎ក!

- ឯណាល្បែង? (សំណាងសួរ)

- ម៉េចក៏ដឹងកើតថាគេកំពុងលេងអាប៉ោង? (រាសីសួរបន្ថែម)

- ហ្អ៎ក! មិនឃើញទេហ៎? (នាយភោគឆ្លើយ) មានអុជចង្កៀង ហើយមានក្ដារប៉ាយផង ថែមទាំងមានមនុស្សច្រើនចោមរោមឈរ មើលច្រើនយ៉ាងនេះ គឺច្បាស់ជាគេកំពុងបាញ់អាប៉ោងហើយ ។

រាសីធ្វើក្បាលងីងើ មួយស្របក់ក៏និយាយឡើង :

- ខ្ញុំថាដូចជាមិនមែនលេងអាប៉ោងទេ បើលេងនៅកណ្ដាលវាល យ៉ាងនេះ ច្បាស់ជាត្រូវនគរបាលក្របួចកមិនខាន... សង្ស័យតែស៊ី ផ្សេងទៀតទេដឹង?

- អញ្ចឹងយើងគិតចូលទៅជិតមើលសិនទៅ ក្រែងមានអីសប្បាយៗ សំរាប់យើងកំសាន្ត ។

- តោះ! បើឥចឹង យើងនាំគ្នាទៅមើលលមើល៍ ក្រែងមានអី សប្បាយភ្នែកដូចល្បែងភោគនិយាយ (សំណាងនិយាយឡើង)

ទាំងបីនាក់ក៏ព្រមព្រៀង ដើរកៀកស្មាទៅមើលទាំងអស់គ្នា។ ពេលនោះ ជាតិទឹកត្នោតជូរកំពុងសណ្ដំសតិអ្នកទាំងបីនៅឡើយ ម្ល៉ោះហើយ ដំណើរគេទាំងបីយោលយោគដូចដើមដូងត្រូវខ្យល់ យោគទៅយោលមក គ្រាន់តែដើរប្រហែលហាសិបម៉ែត្រសោះ ពួក គេម្នាក់ៗ ក៏ហត់ធ្លាក់អណ្ដាតសាជាថ្មីម្ដងទៀតលើសដើម។ នាយ រាសីក៏លាន់មាត់ឡើង:

- ល្បងភោគ! ហើយចុះអំបាញ់មិញពួកយើងអីក៏រត់លឿនសាហាវ ម្លេះ ឥលូវយើងឈប់ម៉ាភ្លែតសោះស្រាប់តែអស់សាំងអាលីងតាម៉ង គ្រាន់តែដើរបួនដប់ម៉ែត្រតែប៉ុណ្ណឹង ក៏មានអារម្មណ៍ហាក់ដូចជាដើរ ១០យោជន៍ឥចឹង ដូចជាមិនចេះដល់....

កាលបើឮដូច្នោះ សំណាងក៏ឆ្លើយភ្លាមថា:

- នែ៎ បើចង់លឿននោះ មានអី! ចាំខ្ញុំទៅហៅប្រពន្ធល្បងភោគមក សាជាថ្មី ធានាថាលឿនឥតស្រណោះ.. បើមិនជឿសាកមើលទេហ៎?

- អូហ៎ ហែស៎ៗ មិនបាច់ក៏បានដែរសំណាង! ខ្ញុំសុខចិត្តទទ្រេត ទទ្រោតចុះ តែមិនហ៊ានភ្ជាល់ជាមួយអាក្បាច់ដងវែកដេញកែងនោះ ទេ បាទ!

- តោះ! កុំអាល័យនិយាយច្រើនអី! ឆាប់ទៅមើលមើស៍ តើគេ កំពុងមានកម្មវិធីវិសេសអីនៅទីនោះ គ្នាដូចជាចង់ដឹងណាស់ (នាយ ភោគតឿន)

អ្នកទាំងបីក៏កៀកស្មាដើរបន្តទៅទៀត។ លុះទៅដល់ជិតស្រាប់ តែគេប្រទះឃើញតាចាស់ម្នាក់ក្នុងសំលៀកពណ៌ស អង្គុយកាន់ក្ដារ ឈ្នួនមួយ រួចនៅពេលគេឈ្ងោកទៅមើលកំរាលលើរាន ឃើញ មានប៉ាយសរសេរក្រវេមក្រវាមទំនងជាអក្សរបុរាណ ទើបដឹងថា តាចាស់នោះ ជាលោកគ្រូហោរទស្សន៍ទាយជោគវាសនារបស់ មនុស្ស។ អ្នកទាំងបីឃើញហើយ ក៏សំលឹងមុខគ្នាទៅវិញទៅមក ធ្វើមុខទំនងខកចិត្ត ត្បិតនោះមិនមែនជាវង់ចាក់អាប៉ោងដូចគេគិត ស្មានជាមុននោះឯណា។ អ្នកស្រុកក៏បន្តវេនម្ដងមួយៗ ចូលអង្គុយ អោយលោកគ្រូទស្សន៍ទាយឱ្យ។ មួយស្របក់ក្រោយមកក៏ស្ងាត់ មនុស្សមិនឃើញមាននរណាចូលខ្លួនមក អោយលោកគ្រូយើងទាយ ទៀតសោះ។ លោកក៏ងើបមុខសំលឹងមុខអ្នក ឈរចោមរោមហើយ ប្រកាសថា :

- សូមអញ្ជើញៗ! ហោរខ្ញុំទាយឆុតឆាប់ សូមប្រញាប់ចូលទស្សន៍ ទាយ គ្រូខ្ញុំមិនចេះនិយាយតែផ្ដេសតែផ្ដាស គឺទាយមើលឆុតឆាប់ រហ័សល្អសំបើមណាស់ ប៉ះតែបានទាយ គឺមិនងាយអោយញាតិមិត្ត ទាំងអស់ខកចិត្ត។ សូមអញ្ជើញៗ !

CHANBOKEO.COM

រំពេចនោះស្រាប់តែនាយភោគឧទានឡើងៈ

- ហោរទាយយកលុយដូច្នេះ... ខ្ញុំថាពិតជាទាយមិនឆុតឡើយ!

មែនហើយ! ការពិតនាយភោគអត់លុយមួយរៀលសោះ តើ អោយនាយចូលអោយគ្រូទស្សន៍ទាយយ៉ាងណា បើគ្មានកំណល់គ្រូ? ដូច្នេះហើយទើបនាយចង់លេងល្បិចខូច ចង់អោយលោកគ្រូទាយ ដោយមិនពិបាកដាក់កំណល់គ្រូ។ ភ្លាមនោះ លោកគ្រូហោរក៏ងាក បែរមកនាយភោគហើយឆ្លើយថា :

- នែ៎នាយជី! លោកគ្រូយើងទាយម៉ាអាយ៉ុសព្រះទៅហើយ មិន ដែលខុសម្តងណាទេ...

- ហ៉ែសៗ! រឿងទាយម្តង មិនដែលខុសមែន តែបើពីរដងឡើងទៅ ច្បាស់ជាលោកតាទាយខុសមិនខានឡើយ។

ឮដូច្នោះ លោកគ្រូទាយខឹងឆេវ ស្រែកដេរឡើងថា :

- ជើ! នាយជី លីបាវខ្សាច់ ប្រកាច់មុនខែ ហ៊ានមកតែវ៉ៃ ប្រមាថ ក្បួនទាយលោកតាយើងផងហ៎ែស? នែ៎ បើថាអត់លុយទេ សុំលោកតាយើងនេះ ទាយត្រង់ៗទៅ មិនបាច់កាច់កុង មើលងេរ យើងទេ!

CHANBOKEO.COM

ឮលោកតាដាក់ចំចំណុចខ្សោយ នាយភោគអត់ហ៊ានមាត់ម៉ាអ៊ឺះ តទៅទៀត។ ស្រាប់តែសំណាង ដែលកំពុងស្រវឹងទឹកត្នោតជូរ ស្រៀងៗ ក៏ពោលវ៉ាសឡើង :

- អូហ៎! បើលោកគ្រូពិតជាចិត្តល្អសណ្តោសកូនចៅក្រីក្រអត់លុយ ពិតមែន សូមលោកគ្រូមេត្តាទស្សន៍អោយកូនចៅដូចខ្ញុំផងនេះបាន ទេហ៎បាទ?

មិនអោយចាញ់ចិត្ត លោកគ្រូក៏ចាប់ដីសសរសេរលើកក្តារឈ្នួន ភ្លាម ហើយសួរនាយថា :

- យើងមិនដែលញ៉ូមទេ ត្រឹមម៉ាទាយអត់កំណល់! ឥលូវប្រាប់មក យើងមើល៏ ថាឯងកើតឆ្នាំអី?

ឮដូច្នោះ សំណាងសប្បាយចិត្តណាស់ ក៏ជំរាបលោកគ្រូតាម ដែល គាត់ត្រូវការភ្លាម។ បន្តិចមកលោកគ្រូក៏សួរថា :

- មើលនាយជី! តើនាយចង់ឱ្យតាទស្សន៍ទាយអំពីអ្វីដែរ?

- បាទ! លោកគ្រូ! គឺខ្ញុំ.... នែក.. ចង់ទាយថា តើខ្ញុំនេះដល់គូព្រេង អង្កាល់ដែរ? ហើយតើនាងជានារីស្រស់ស្អាតដែរឬទេ?

លោកតាក៏ចាប់ដីស គូសវ៉ាសភ្លាម។ សំណាងធ្វើមុខញញឹមទឹក សង្ឃឹមក្នុងចិត្តថា គេមានរូបសង្ហារយ៉ាងនេះ ច្បាស់ជាមានគូព្រេង ជានារីរូបស្អាត ហើយជាអ្នកមានលុយកាក់ទៀតផង។ កំពុងតែ ស្រមើស្រម៉ៃ ស្រាប់តែ...លោកតាងើបមុខឡើង សំលឹងសំណាង ហើយក៏សំលឹងជុំវិញទីនោះ រួចក៏ជ្រួញចិញ្ចើម។ ឃើញដូច្នោះ សំណាងនឹកពិភាល់ក្នុងចិត្ត ក៏សួរលោកគ្រូថាៈ

- លោកតា! តើគូព្រេងខ្ញុំនៅឯណាដែរ? អង្កាល់បានជួបគ្នា?

លោកតាបែរមើលចុះឡើងមួយស្របក់ទើបឆ្លើយថា :

- នាយជីឯងជិតបានជួបគូព្រេងហើយ ពេលបន្តិចទៀតនេះ ហើយ ត្រូវរៀបការនឹងគ្នា មិនយូរមិនឆាប់....

ឮដូច្នោះ សំណាងអរភើត :

- អូហ៎! ហើយតើនាងមានរូបឆោមយ៉ាងណាដែរ?. ជាអ្នកមានដែរ
ទេហ៎ លោកតា?

- តាមិនដឹងទេហ៎ ទាល់តែចៅឯងពិនិត្យខ្លួនឯងហើយ!

- អញ្ចឹងនាងជាអ្នកណា? នៅឯណាដែរលោកតា?

ស្រាប់តែលោកតាងើបមុខឡើង ចង្អុលទៅនារីមួយរូបមានមុខ មាត់ប្រលាក់ប្រលូស សក់កន្ទ្រឹងកន្ទ្រើង បង់កក្រមា កំពុងរែក ពោតស្ងោរដើរលក់តាមផ្លូវ :

- នុ៎ះ គឺនាងនោះហើយ ជាគូព្រេងរបស់ចៅជីឯងនោះអី!

- ពុទ្ធោ! ........

សំណាងលាន់មាត់ ខកចិត្ត ប្រហោងពោះធ្លុងតែម្តង ។ គ្រាន់តែ នាយយើងក្រលេកឃើញនាងកាលណា ក៏នឹកអន់ចិត្តណាស់ហើយក៏ ខឹងនឹងមាណវីមួយរំពេច ដែលនាងមកដើរកាត់ទីនោះ ផ្តេសផ្តាស ខុសកាលខុសវេលា ធ្វើអោយលោកគ្រូទាយបន្លំទំលាក់ជោគជតា របស់នាយយ៉ាងទាបត្រដាប មកមានគូព្រេងជាក្រមុំរែកពោតស្ងោរ លក់ទៅវិញ ។ ជាតិទឹកត្នោតជូរនៅត្រាំក្នុងសរសៃឈាមរបស់ នាយយើងក្រាស់ក្រែលនៅឡើយ ។ កាលបើនាយយើងខឹងខកចិត្ត ពេក ក៏អស់សតិនឹងគិតខុសត្រូវរលីង ។ ភ្លាមនោះ សំណា ឈ្ងោក មុខចុះដី លូកដៃរាវយកដុំថ្មមួយដុំគប់នារីនោះភឹង ចំកណ្តាល ក្បាលនាងផ្លូក់ ។ ធិតានោះក៏ស្រែកវ៉ាសឡើងថា :

- អែយួយ! ឈឺណាស់! ឈាមក្បាលខ្ញុំហើយ! ពីណាគេលេង គប់ដុំថ្មអីផ្តេសផ្តាសយ៉ាងហ្នឹង?

នាងក៏ទំលាក់អំរែកចុះ ហើយបែរមុខមកគួកនទាំងបីភ្លាម ។ លុះសំណាងក្រលេកឃើញឈាមហូរស្រក់តាមសក់ចុះមកលើថ្ពៃ មុខរបស់នារីអ្នកលក់ពោតស្ងោរ ក៏ភិតភ័យព្រិលភ្នែកច្រលំថាខ្មោច លងនាយ ។ កំលោះយើងក៏ស្ទុះរឹង ផាយចោលក្តារប៉ាយមិនហ៊ាន ងាកក្រោយឡើយ ថែមទាំងភ្លេចជំរាបលាលោកតាដែលទស្សន៍ ទាយនោះទៀតផង ។ លុះឃើញនាយផាយរត់យ៉ាងលឿនបាត់ ស្រមោលរកចំណាំមុខអីក៏មិនទាន់ ដេញក៏មិនទាន់ មាណវីយើងក៏ យកក្រមារុំក្បាលកុំអោយហូរឈាមថែមទៀត ហើយបែររែក ពោតស្ងោរដើរចេញទៅវិញទៅ ។ ពេលនេះ

CHANBOKEO.COM

គូកនបីមុមក៏ត្រលប់ ជានៅសល់តែពីរគ្រឿង កំពុងធ្វើមុខឡឹងឡង់ដាក់គ្នាទៅវិញ ទៅ មក។ ភ្លាមនោះ លោកគ្រូក៏សួរបន្ថែមទៅអ្នកទាំងពីរថា :

- យ៉ាងម៉េច នាយជីទាំងពីរ? ខ្លាចលោកគ្រូទាយឆុតឬអ្វី បានមិន ហ៊ានឱ្យលោកគ្រូទាយអោយបន្ត?

កុំអោយចាញ់ចិត្ត រាសីក៏ធ្វើឫកពាដូចគ្រាន់បើហើយពើងទ្រូង ដាក់លោកតាភ្លាម ព្រមទាំងស្រដីថា :

- អញ្ចឹង បើលោកតាពិតជាទាយឆុតមែន សូមមេត្តាទស្សន៍មើល ជោគជតារបស់ចៅផងបាទ ក្រែងមានសំណាងធំដុំនឹងគេ។

លោកតាក៏ចាប់ដេញដោលថ្ងៃខែកំណើតសាថ្មី ហើយក៏គូស វាស១ លើក្តារឆ្នួនមួយស្របក់ ទើបឆ្លើយថា :

- ហ៊ឺ! ឯងនេះមានជតាខុសគ្នាពីមិត្តរបស់ឯងអំបាញ់មិញឆ្ងាយ ណាស់ ហៅមិនឮទេ...

រាសីឮហើយ នឹកអរភើត :

- មែនឬលោកតា? តើខ្ញុំជាមនុស្សមានសំណាងជាងមិត្តរបស់ខ្ញុំ មែនទេបាទ?

- នរណាថាឯងមានសំណាងជាងនោះ ? (លោកតាឆ្លើយ)

- អូហ៎.... បើអញ្ចឹងយ៉ាងម៉េចវិញលោកតា? (រាសីទំលាក់ទឹកមុខ)

- គឺ..ដល់ថ្ងៃដែលមិត្តរបស់នាយជីឯងអំបាញ់មិញគេរៀបមង្គលការ ចូលផ្សំដំណេកក្រេបទឹកឃ្មុំព្រះចន្ទ័នោះ... នៅវេលាយប់ដដែល ចំ ពាក់កណ្តាលអាធ្រាត នាយជីឯងនេះ នឹងត្រូវដេកងាប់ចាកលោក នេះទៅវិញព្រមពេលជាមួយគ្នាហ្នឹងដែរ...

- ពុទ្ធោ! ធម្មោ!.... (រាសីលាន់មាត់) ខ្ញុំមិនជឿលោកតាឯងទេ! ហេតុអីក៏ទាយអោយពួកម៉ាកខ្ញុំល្អ តែទាយអោយខ្ញុំយីអ៊ុនដាក់ត្រូវ ដេកងាប់ទៅវិញ? លោកតាមានប្រសាសន៍តែផ្តាស.. គឺខ្ញុំ.... ខ្ញុំមិនងាប់ទៅណាំទាំងអស់ ហើយក៏មិនជឿហោរលោកតាដែរ!

រាសីស្វាងពីស្រវឹងទឹកត្នោតជូររលីង កាលបើឮលោកតាទស្សន៍ អោយថាត្រូវស្លាប់ថ្ងៃដែលពួកម៉ាកខ្លួនផ្សំដំណេក។ នាយយើងខឹង ខ្លាំងពេក ក៏ស្ទុះងើបរឹងរត់ចេញទៅយ៉ាងលឿន ដោយមិនខ្ចីលា លោកតាមួយម៉ាត់ មិនខុសពីសំណាងដែលជាមិត្តរបស់ខ្លួនឡើយ។ រំពេចនោះ ភោគនៅអង្គុយតែម្នាក់ឯងធ្វើឫកអេះអុញ១ ហាក់ដូច ជាចង់ទាយដែរតែមិនហ៊ាន ត្បិតខ្លួនទើបតែរិះគន់ប្រមាថលោកតា មុននេះបន្តិច។ ប៉ុន្តែ លោកតាហោរ ហាក់ដូចដឹងចិត្តនាយភោគ ណាស់។ គាត់មិនចាំអោយនាយភោគសុំទាន់ទេ ក៏សួរទៅនាយ ភ្លាមថា :

- នែ៎ នាយជី! ប្រាប់ខែឆ្នាំដែលឯងកើតអោយយើងភ្លាមមើល៍...

CHANBOKEO.COM
CHANBOKEO.COM

ភោគក៏ឆ្លើយទាំងខ្លាចផង ភ័យផង អរផង.. ខ្លាចលោកតា ទាយឆុត ប៉ះចំជតាចុះត្រដាប តែក៏អរភើតដែរ ព្រោះចង់កើបលាភ ព្រមទាំងនឹកសង្ឃឹមថាជតារបស់ខ្លួន មិនយ៉ាប់យុឺនដូចពីរនាក់មុន ពេកនោះទេ។ បន្តិចក្រោយមកលោកតាក៏សួរទៀតថា :

- តើនាយជីឯងចង់ទាយពីអ្វីដែរ?

នាយភោគយកដៃអេះក្បាល រួចក៏ឆ្លើយវិញថា :

- បាទ! ខ្ញុំគិតថាចង់ទាយពីគូព្រេង! (នាយភោគនិយាយហាក់ដូច ជាកំពុងចង់បែកគំនិតរកប្រពន្ធថ្មីមួយទៀត)

- អូហ៎! ចាំបាច់ទៅរកថី ម៉ាត្រឹមរកគូព្រេងនោះ? (លោកតា ឆ្លើយឡើង) នុះហ្ន៎! មកដល់ហើយ លឿនទាន់ចិត្តណាស់ !

ភោគងាកតាមដៃដែលលោកតាចង្អុលប្រាប់ ស្រាប់តែប្រទះ នឹងនាងប្រមូលដែលលីដងរែកមកដល់ព្រឹបដែរ :

- ជើ! តាប៉ិភោគ! ថ្លើមធំ ហ៊ានទាំពួកម៉ាក ដើរលេងមិនចូលផ្ទះ ផងហ្ន៎ស?

ភូស! ប៉ុង! ប្រាវ! នាងប្រមូលយារដងរែកដេញវ៉ៃនាយ ភោគឡើងចលាចលអស់ម៉ាផ្សារ។

- អៃយ៉ូយ! អូនប្រមូល! ហេតុអីក៏លែងខ្លាំងដៃម្ល៉េះ? ម៉េចមិន ទុកពេលអោយប្ដីរាំថ្វាយគ្រូប្រុងប្រយត្ន័ខ្លួនមុនអីខ្លះទេ?

ថាហើយ នាយភោគក៏រត់បាត់ស្រមោលទៅ។ ហេតុតែខ្លួន នាងរាងម៉ាប់បន្តិច គ្រាន់តែយារដងរែកដេញវ៉ៃនាយភោគតែពីរបី ភូសប៉ុណ្ណោះ នាងប្រមូលក៏ហត់ស្ទើរដកដង្ហើមមិនដល់គ្នា។ ភ្លាម នោះ នាងប្រមូលដាក់ភ្នែកទៅចំក្ដារប៉ាយទស្សន៍ទាយ ហើយឃើញ លោកគ្រូហោរអង្គុយមើលនាងវាយប្ដីធ្វើមុខភាំង។ នាងក៏ដើរចូល មកជិតហើយសួរថា:

- លោកតា! តើលោកតាទាយឆុតទេហ៎?

- អើ! គេគ្រប់គ្នាថា លោកតាទាយឆុតណាស់! តែបើនាងមិនជឿ សាក ល មើលម្ដងទៅ ឆុតមិនឆុត គង់តែដឹងទេហ៎!

- បើមិនឆុត លោកតាមិនបាច់យកកំណល់គ្រូទេ!

- ចុះបើឆុតវិញ  នាងមានអ្វីជាកំណល់ដែរ?

CHANBOKEO.COM




- គឺខ្ញុំនឹងរៀបកំណល់តាមលោកគ្រូកំណត់!
- ច្បាស់ហើយ?
- ចាស!
- អញ្ចឹងនាងចង់ដឹងពីអ្វីដែរ?
- គឺអញ្ចេះណ៎លោកតា!

EO . COM

តាំងពីរៀបការហើយកាលណាមក៏ ឃីអ៊ុនខ្ញុំវាចេះតែដាក់ រកស៊ីមិនកាក់កបសោះ មិនដឹងថាដល់អង្កាល់ខ្ញុំនឹងមានលាភ កើតជាអ្នកមាននឹងគេម្តង?

លោកតាកចាប់វាយជើងលេខមួយស្របក់ រួចក៏មានប្រសាសន៍ ប្រាប់នាងថា :

- កុំភ័យអី! ចូរនាងនាំប្តីចេញទៅរកស៊ីនៅភ្នំពេញទៅ នោះនឹងបាន ទទួលលាភធំមួយដោយចៃដន្យ ដែលនឹងធ្វើអោយគ្រួសារនាង ក្លាយជាអ្នកមានធំមិនខានឡើយ ។

នាងប្រមូលព្យួហើយសប្បាយចិត្តណាស់ ក៏សំពះជំរាបលាលោក តា ត្រលប់មកផ្ទះវិញ ភ្លេចការម៉ូម៉ៅក្នុងចិត្តអស់រលីង ។

០០០០០០០០០០០០០០០០

០០០០០

០

CHANBOKEO.COM
CHANBOKEO.COM

## វគ្គទី៤
## បំណន់មុខព្រះអង្គដង្កើ

រាសីដើរយំគគ្រូកតាមផ្លូវ ណានឹកភ័យខ្លាចងាប់មុនខ្លួនស្លាប់... ណាមួយខឹងនឹងលោកតាហោរដែលទស្សន៍ថា នាយនឹងស្លាប់មិនយូរ មិនឆាប់ ។ តូចចិត្តពេក រាសីក៏រត់ទៅអង្គុយក្រោមដើមដូងមាត់ ស្ទឹងសង្កែ ចង់លោតទឹកស្ទឹងសំលាប់ខ្លួនបន្តិច ស្តាយជីវិតបន្តិច... ជាពិសេសគឺស្តាយវ៉ៃយកំលោះរបស់ខ្លួនហ្នឹងតែម្តង ។ នាយរាសីយើង ស្រដីរអ៊ូតែម្នាក់ឯងថា :

- ព្រះជាម្ចាស់អើយ! បំណាច់នឹងស្លាប់ដដែល តើរស់នៅដើម្បី អ្វីទៀត?

នាយបំរុងលោតចុះទៅក្នុងទឹកស្ទឹងទៅហើយ ស្រាប់តែមានដៃ មួយមកកេះ :

- នែ៎ សំលាញ់! ចង់មកលោតទឹកស្ទឹងអីទាំងយប់?

រាសីងាកក្រោយមើល ឃើញសំណាងសើចគ្រហាញដាក់ ស្រាប់ តែនឹកដូរចិត្តមកវិញលែងចង់ស្លាប់តែម្តង ហើយបែរឆ្លើយថា :

- ថ្ងៃនេះដូចជាស្អុះស្អាប់ពេក... បានជាចង់លោតចុះស្ទឹងម៉ាសន្ទុះ អោយត្រជាក់ខ្លួនបន្តិច

- ហែស់ៗ! មិនមែនទេដឹង ល្បងរាសី? សង្ស័យតែល្បងឯងមាន ខោតែមួយហើយ បានជាបន្លំមកងូតទឹកស្រាត ពេលយប់ដូច្នោះ មែនទេ?... មែនទេ?

- ហ៉ែសៗ...

មែនហើយ ពិតដូចសំណាងថាមែន រាសីមានខោតែមួយចង្កេះ នោះឯង ហើយក៏ស្លៀកវារាប់អាទិត្យមកហើយ មិនទាន់ដែលបាន បោកម្តងនៅឡើយទេ ។ រាសីនិយាយហើយ ក៏ឈ្ងោកមើលខោ របស់សំណាងវិញ :

- ខ្ញុំថា ល្បងក៏ស្លៀកតែអាម៉ូដមួយហ្នឹងយូរដែរហើយ... ហេតុអីក៏ ចិត្តដូចខ្ញុំអីក៏ដូចម្លេះ? ទិញខោរាប់ផ្លូន ប៉ុន្តែរើសយកម៉ូដតែមួយ មុខគត់ ហ៉ែសៗៗ......

- ហ៉ែសៗ! អញ្ចឹងហើយណ៎ា បានជាយើងធ្វើពួកម៉ាកនឹងគ្នាបាន នោះអី ព្រោះចិត្តថ្លើម យើងវាដូចគ្នាណាស់... ហែសៗ

CHANBOKEO.COM

ទាំងពីរនាក់ក៏សើចរីករាយឡើង ។ ឯនាយរាសីក៏ភ្លេចរឿងភ័យ ងាប់មុនអាយុ នោះទៅ ។ បន្តិចមក គេក៏លាន់មាត់ព្រមគ្នាឡើង :

- អីយ៉ា! ពេលនេះមិនដឹងល្បងភោគយ៉ាងម៉េចហើយទេហ្ន៎?

ទាំងពីរនាក់យកដៃខ្ទប់មាត់ ស្រម័យឃើញនាងប្រមូលលីដង រំរែកដេញពីក្រោយកែងនាយភោគ ។ សំណាងក៏លាន់មាត់ថា :

- ថ្ងៃស្អែក តើគាត់នៅសល់ជីវិតមកជួបយើងវិញដែរឬទេហ្ន៎?

- បើឥចឹង ចាំព្រលឹមឡើងយើងទៅស៊ើបការណ៍ (រាសីឆ្លើយ)

- មែនហើយ! ពេលនេះ គ្នាអាងុយដេកហើយ លែងចង់ទៅណា ហើយណាំសំលាញ់ ។

- រួចចុះល្បងសំណាងឯងទៅរកដេកពួនឯណាដែរ?

- យី! ទៅខ្វះអី កៅអីថ្មសាធារណៈ តាមមាត់ស្ទឹងសង្កែ ក្រោម ពន្លឺដួងខែ ខ្យល់អាកាសត្រជាក់រហើយស្រួលផង...

- គ្រាន់តែមូសវាមកជំរាបសួរបន្តិច...

- ចៃដន្យខ្ញុំជាមនុស្សចិត្តទូលាយរាប់អានញាតិតាំងពីដើម... បើវា ជំរាបសួរខ្ញុំ ខ្ញុំក៏សូមទះសំពះសួរវិញតែប៉ុណ្ណឹង...

- អីយ៉ា! ឡូយផងគេមែន ។

ថាហើយ ទាំងពីរនាក់ ក៏ប្រាសខ្លួនដេកលក់ស្រមុកខុរ ទល់ខ្នង គ្នាលើកៅអីថ្ម ក្រោមដើមដូងមាត់ស្ទឹងសង្កែ ដែលមានពន្លឺខែរះ បំភ្លឺប្រិម១ ដល់វិមានឥតដំបូលរបស់គេទាំងពីរនាក់ ។

ព្រឹកស្អែកឡើង....

គេទាំងពីរនាំគ្នាដើរសំដៅទៅផ្ទះនាយភោគឯម្តុំវត្តកំផែង...

- ល្បងរាសីហ្ន៎ស! តើថ្មើរនេះ ល្បងភោគចូលផ្ទះវិញហើយនៅ?

- មិនដឹងទេ ល្បងអើយ! យើងប្រថុយទៅមើលលេងទៅ ។ បើ គាត់មិននៅ ចាំរត់ ។ យ៉ាងណា១ យើងទាំងបីនាក់ជាមិត្តនឹងគ្នា ជួយជាដៃជើងមិនបាន ធ្វើត្រឹមតែភ្នែកច្រមុះក៏បានដែរ...

- មានន័យថាម៉េចទៅល្បង?

- គឺប្រើភ្នែកមើលថា តើល្បងភោគឋិតក្នុងគ្រោះថ្នាក់ហឺអត់...

- ចុះបើអត់...

- យើងក៏រួចខ្លួន...

- ចុះបើគាត់កំពុងត្រូវច្រាបជាន់...

CHANBOKEO.COM

- យើងក៏មានផ្លូវផាយនោះអី... យីអើ...

-ថ្ងៃនេះ ល្បងរាសីឯងដូចជាបានមាត់បានក ព្រោកប្រាជ្ញគួរសម ដែរតើហ៎

- ហ៉ែសៗ.... ចេះតិចតួច... រៀនតាមល្បងឯងហ្នឹងណា៎!

មួយសន្ទុះក្រោយមក គេទាំងពីរក៏មកដល់មុខផ្ទះនាយភោគ ស្រាប់តែឮសំលេងស្រែកដូចជ្រូកគេចាក់ក។ សំណាងលាន់មាត់:

- សង្ស័យតែល្បងភោគកាប់ជ្រូកសែនដូនតាហើយ...

- ខ្ញុំថាមិនមែនទេ... ប្រហែលជាសំលេងចោរដែលត្រូវដំបងរបស់ បងប្រមូលហើយ ត្បិតអីវាដឹងថាល្បងភោគមិនចូលផ្ទះ បានជាវា ថ្លើមធំចូលលួចឥវ៉ាន់...

- បើគីចឹង យើងឆាប់ទៅមើលភ្លាមមើល៍

លុះគេទាំងពីរចូលទៅដល់ ឃើញនាងប្រមូលកំពុងជាន់កនាយ ភោគយកន្សែងចុកមាត់ ហើយយកខ្សែចងដៃជើងទៀត។ រាសី ឃើញហើយក៏ស្ទុះឃាត់ :

- មានរឿងអ្វីបងស្រី ហេតុអ្វីក៏ចាប់ល្បងភោគចងយ៉ាងនេះ?

- អឺ! គឺមកពីតាប៉ិភោគមិនព្រមទៅភ្នំពេញតាមខ្ញុំ...

- ហើយចុះបងស្រីចង់ទៅភ្នំពេញធ្វើអី?

- ព្រោះលាភធំរបស់យើងកំពុងតែរង់ចាំទីនោះ។

- លាភធំ? (សំណាងនិងរាសីលាន់មាត់ព្រមគ្នា)

- មែនហើយ! បើអ្នកទាំងពីរជួយខ្ញុំ ចាប់តាប៉ិភោគយកទៅដល់ ភ្នំពេញបាន នោះខ្ញុំនឹងចែកលាភអោយខ្លះពេលខ្ញុំទទួលបានមក យល់ព្រមទេ?

សំណាងឮហើយក៏ស្ទុះចូលភ្លាមដោយមិនគិតអ្វីច្រើន :

- មែនឬបងស្រី? ឥចឹងម៉ោះ ខ្ញុំជួយ!

តែនាយភោគគេបំរះខ្លាំងណាស់ មិនអាចអោយសំណាងចាប់ នាយលី ដោយងាយបាន ម៉្លោះហើយសំណាងក៏បែកប្រាជ្ញ :

- ម៉ោះជួយចងដៃជើងល្បងភោគសែងវិញ

CHANBOKEO.COM
CHANBOKEO.COM




- តែ....

- គ្មានតែអីទៅ... ម៉ោះជួយសែងភ្លាមមក៏....

រាសីនិងសំណាងសែងនាយភោគដល់ចំណោតឡានក្រុង ដោយ  មាននាងប្រមូលជាអ្នកស្ពាយបង្វិច  ដើរតាមពីក្រោយ រួចហើយក៏នាំគ្នាឡើងជិះឡានចេញទៅ....

ក្រុងភ្នំពេញ....

នៅមុខដំណាក់ព្រះអង្គដង្កើ... មុខព្រះបរមរាជវាំង....

បួននាក់ រាសី សំណាង នាយភោគនិងនាងប្រមូលជាភរិយា បានយកផ្កាឈូកនិងធូបទៀន ទៅបន់ព្រះតែរៀងៗខ្លួន។  នាង ប្រមូលបន់ថា :

-  ឱព្រះអង្គដង្កើដ៏មានបារមីសក្តិសិទ្ធិ៍អើយ! សូមព្រះអង្គជួយបំភ្លឺ ផ្លូវឱ្យខ្ញុំម្ចាស់បានជួបប្រទះលាភយ៉ាងធំឆាប់ៗនេះ។ សូមអោយ ទំនាយលោកតាហោរាក្លាចជាឆុតឆាប់កុំខាន សាធុ!!! ឆុត! ឆុត! សាធុ!! ឆុត! សាធុ!

រីឯនាយភោគវិញបន់ថា :

- សូមអោយខ្ញុំបានជួបគូព្រេងថ្មី ដែលមិននិយាយជាមួយខ្ញុំដោយ ភាសាដំបងនិងដងរែកតទៅទៀត.... ហ្វាំង... សាធុ!!! សូមអោយ ទំនាយលោកតាហោរាខុសទាំងអស់... ហ្វាំង.... ហ្វាំង.... សាធុ!!....

កុំឆុត! កុំឆុត! សាធុ!

សំណាងវិញក៏បន់ដែរថា :

- សូមអោយខ្ញុំមានគូព្រេងជានារីរូបស្រស់ដើរតួសំដែងម៉ូដ ថតខ្សែ ភាពយន្ត ឬតួតារាម៉ូដែលស្អាតៗ លើក្របសៀវភៅទស្សនាវដ្ដីប្រចាំ ប្រទេសខ្មែរ ។ សូមអោយខ្ញុំចៀសអោយផុតគូព្រេងលក់ពោតស្ងោរ នៅបាត់ដំបងផងចុះ សាធុ! សូមអោយលោកតាហោរាទាយខុស អោយអាលីងម៉ត់... សាធុ....!!! ខុស! ខុស! ខុស! សាធុ!!

ចំណែកវាសីក៏រញ្ជាក់រញ្ជ័រទៅរកអុជធូបដែរ ស្រាប់តែមានវង់ ភ្លេងពិណ្យពាទ្យប្រគំឡើងភ្លាម... មែនហើយ! ថ្ងៃនេះជាថ្ងៃសីល វង់ភ្លេងបុរាណតែងតែមកប្រគំជាប្រចាំនៅទីនោះ ។ ភ្លាមនោះវាសី ក៏បន់ឡើងថា :

- សូមអោយបារមីថ្ងៃសីល ជួយគ្រប់គ្រងជីវិតរបស់ខ្ញុំអោយអាយុ វែង មិនស្លាប់មុនអាយុស ដូចពាក្យលោកតាទស្សន៍ទាយនៅ បាត់ដំបងឡើយ សាធុ! សូមអោយអ្វីដែលលោកតាទស្សន៍ទាយ ខុសទាំងអស់កុំខាន.... សាធុ!! សូមអោយខ្ញុំរស់ឡើងវិញ សាធុ! រស់! រស់! រស់! សាធុ!....

បួននាក់ បន់ព្រះក្នុងបំណងផ្សេងគ្នា... តើព្រះអង្គដង្កើមាន បារមីសក្ដិសិទ្ធិ៍អាចផ្លាស់ប្ដូរដំណើរជីវិតរបស់អ្នកទាំងអស់គ្នាបានដែរ ឬក៏យ៉ាងណា? ឬក៏ការទស្សន៍ទាយរបស់លោកតាហោរសក្ដិ៍សិទ្ធិ ជាជាង? តើបំណន់របស់គេទាំងបួននឹងបានសំរេចផលបំណងឬក៏ បានលទ្ធផលបែបណាទៅវិញ?.....

នៅរាត្រីថ្ងៃដដែល....

អ្នកទាំងបួនអត់ផ្ទះនឹងទៅ អត់លុយនឹងទិញអាហារបរិភោគ មាន សល់ត្រឹមតែបាយស ម៉ាកញ្ចប់ស្លឹកចេកមួយម្ល៉ោះហើយក៏នាំ គ្នាកាយញ៉ុកៗបំពេញគំលានទៅ ។ បន្តិចមក គេក៏នាំគ្នាដេករកេត រកូតតាមក្រោមដើមឈើ បន់ព្រះផង ឃ្លានផង កូរពោះគ្រូកៗ ប្រណាំងគ្នាផង ។

យប់ជ្រៅបន្តិចហើយ... មនុស្សម្នាក៏ពន្លត់ភ្លើងចូលដេក ។ រីឯ ចរាចរក្នុងទីក្រុងក៏ចុះថមថយទៅដែរ ។ រស្មីក្នុងទីក្រុងក៏ប្រែជា ងងឹតជាងមុនហើយក៏ស្ងាត់ជាងមុនបន្តិច ប៉ុន្តែភឿនទាំងបួនរូបដេក មិនលក់សោះ ។ គេប្រែខ្លួនទៅប្រែខ្លួនមកតែរវៀងៗខ្លួន ។ រំពេចនោះ ស្រាប់តែមានជនពីររូបលីការុងមួយម្នាក់រត់កាត់ទីនោះ ហើយមាន

CHANBOKEO.COM

មនុស្សជិះម៉ូតូតាមបាញ់ពីក្រោយផង ។ ភ្លាមនោះ ជនលីការុងក៏រត់ ជាន់ជើងនាងប្រមូលដែលកំពុងសំងំដេក ។ នាងប្រមូលស្រែកវ៉ាស ឡើង ច្រលំស្មានថាជានាយភោគជាន់ ក៏លើកដងរែកដេញវាយ នាយភោគដែលអង្គុយស្ងាបមិនដឹងអី ។ នាយភោគភ័យណាស់ ក៏ស្ទុះទៅប្រវាយយកការុងពីបុរសម្នាក់ ដែលកំពុងលីរត់នោះយក មកទប់ទល់នឹងដងរែករបស់នាងប្រមូល ។ រីឯបុរសចំលែកវិញក៏ខំ ប្រឹងប្រវាយប្រតប់អូសយកការុងរបស់នាយត្រលប់យកទៅវិញ តែ ក៏ត្រូវនឹងដងរែករបស់នាងប្រមូលយ៉ាងដំណំ ។ នាយភោគរត់ចុះ រត់ឡើងក៏រត់ជ្រុលហួសផ្លូវរមៀលតាមច្រាំងចោតធ្លាក់ទឹកទន្លេក្ដូង! ការុងក៏អណ្ដែតឡើង ។ នាយភោគភិតភ័យខ្លាំងណាស់ ក៏ស្រវា អោបការុងបណ្ដែតខ្លួនតាមខ្សែទឹក រហូតដល់ចុងស្ពានជ្រោយចង្វារ ទើបអាចហែលឡើងគោកវិញបាន ។ ដើម្បីកុំឱ្យវង្វេង នាយយើងក៏ ដើរសរសៀរតាមឆ្នេរទន្លេចុះឡើង៧តំរង់មក ដល់កន្លែងដើមរបស់ ខ្លួនវិញ.....

CHANBOKEO.COM

និយាយពីនាងប្រមូលម្ដង....

កាលបើកំពុងជាប់ដៃជាមួយបុរសចំលែក នាងមិនបានចាប់ ភ្លឹកទេថាប្ដីរបស់ខ្លួនធ្លាក់ទឹកទន្លេបាត់ទៅហើយ ។ ភ្លាមនោះ ស្រាប់ តែនាងឮសូរគ្រាប់កាំភ្លើងផ្ទុះលាន់ផាំងក្បែរត្រចៀក ។ ពេលនាង ងាកបែរទៅរកទិសសំលេង ក៏ឃើញបុរសម្នាក់ស្លៀកខ្មៅជិះម៉ូតូ ដេញតាមបាញ់បុរសពីរនាក់ទៀតដែលលីការុងរត់ ។ នាងប្រមូលក៏ លាន់មាត់ឡើងថា :

- យីអើ ស្រុកភ្នំពេញនេះពិតជាប្លែកមែន! មានគេថតកុនទៅពេល យប់ មានចោរ មានមនុស្សដេញបាញ់គ្នាឡូយណាស់តើ...

គិតដូច្នោះហើយ នាងប្រមូល ក៏នឹកភ្នកចង់ចូលកាម៉ារ៉ានឹងគេ ដែរក្រែងមានរូបនឹងគេក្នុងខ្សែភាពយន្ត ពេលគេយកទៅបញ្ចាំង ។ នាងក៏យកដងរែកទៅខ្ទាស់កង់ម៉ូតូភ្លែត ស្រាប់តែម៉ូតូដួលគ្រាំង ។ បុរសដែលជាអ្នកជិះក៏ដួលខ្ទាតទៅម្ខាងព្រូស ហើយច្រលំគាស់កៃ កាំភ្លើងត្រូវក្បាលពោះខ្លួនឯង ផាំង! បុរសនោះស្រែកអូយមួយ ម៉ាត់ ហើយក៏បាត់មាត់ទៅ ។ ឯបុរសពីរនាក់ទៀតក៏ផាយបន្តដំណើរ ទៅមុខទៀត ។ រំពេចនោះ ស្រាប់តែក្រុមនគរបាលសន្តិសុខ ក៏បាន មកដល់ហើយក៏ពន្ធ័ចាប់បុរសទាំងបីចេញទៅ ។ មុននឹងចេញដំណើរ នាយតំរួតនគរបាលមួយរូប ចេញមុខមកសរសើរនាងប្រមូលថា :

- អរគុណបងស្រីណាស់ ដែលមានចិត្តក្លាហានជួយប្រតិបត្តិការចាប់ ជនល្មើសរត់ពន្ធអាភៀនទាំងបីរូបនេះ! បងស្រីជាពលរដ្ឋដ៏ល្អគួរឱ្យ សរសើរមែន! ក្រុមនគរបាលយើង សូមគោរពនូវសន្ដានចិត្តដ៏ ប្រសើរនេះ ។

នាងប្រមូលឈរធ្មើភ្នែកស្លឹង លើកដៃសំពះតបទៅលោកនាយ តំរួតវិញទាំងភ្ញាក់ផ្អើល ។ នាងនឹកក្នុងចិត្តថា :

- ពុទ្ធោ! ពួកនេះជាចោរមែនទែនតើហ៎! មិនមែនកំពុងថតកុន ឯណា? ឱម្ចាស់ថ្លៃ ក្តាមប្រែម្ហូរក្រូចឆ្មារ... !!

លុះនាងបែររកមើលនាយភោគ ស្រាប់តែបាត់ស្រមោលទៅ ឃើញសល់តែស្បែកជើងមួយចំហៀង នៅជ្រុះមាត់ច្រាំងទន្លេ :

- ពុទ្ធោអើយ! ល្បងភោគធ្លាក់ទឹកទន្លេបាត់ហើយទេដឹង?

ស្រាប់តែនាងប្រមូលដាក់ខ្លួនចុះ យំហ៊ូភ្លាមតែម្តង ។

និយាយពីសំណាងនឹងរាសីម្តង ។ គេទាំងពីរឃើញហេតុការណ៍ សព្វគ្រប់ទាំងអស់ ប៉ុន្តែគេទាំងពីរមិនហ៊ានលូកមាត់សោះ ត្បិតគិត ថាជារឿងជំលោះប្តីប្រពន្ធ ។ លុះដល់ឃើញមានមនុស្សដេញបាញ់គ្នាពេញផ្លូវ ប្រមាត់អ្នកទាំងពីរក៏រួញតូចប៉ុនស្រមោច រិតតែលែង ហ៊ានអើតមុខចេញជួយអ្នកណាឡើយ គ្រាន់តែរត់ហាក់តាមមើល នាយភោគដែលធ្លាក់ទឹកនោះហើយក៏នាំគ្នាឈរធ្មើមិងមាំង មិនដឹងថាត្រូវធ្វើយ៉ាងណាទៀត ។ ទាំងពីរនាក់មិនហ៊ានហក់ចុះទន្លេទាំង ងងិតទេ ខ្លាចកុនស្លាប់ទាំងអស់គ្នាក្នុងទឹកនោះ ម៉្លោះហើយក៏នៅ អេះអុញ១ រហូតដល់ក្រុមប៉ូលីសចូលមកធ្វើអន្តរាគមន៍ នាំអ្នកជាប់ ពិរុទ្ធទៅអស់ ទើបនាំគ្នាវារទើម១ចេញមក ។ ពេលនោះ អ្នកទាំង ពីរបានឃើញនាងប្រមូលអង្គុយទ្រហោរយំរៀបរាប់ :

- ល្បងភោគអើយ! បើស្លាប់ទៅជាខ្មោចហើយ កុំមកលងខ្ញុំវិញ ណា៎! ខ្ញុំខ្លាចខ្មោចណាស់! ណា៎ប្តីសំលាញ់អើយ...

- បងមិនទាន់ងាប់ទេ  អូនប្រមូល!

ប្រមូលងាកផាំងឃើញនាយភោគពុនការុង ដើរសស្លាក់សស្លើត មកដល់ភ្លាម ។ នាងក៏ស្ទុះងើបឡើងយ៉ាងរហ័ស :

- ពុទ្ធោអើយ! ខ្ញុំខំតែយំស្រណោះ មិនដឹងសោះថាល្បងឯងនៅ រស់អោយឱ្យជ្រងោសោះ!

សំណាងនិងរាសីក្រលេកឃើញនាយភោគមកដល់ ក៏ស្ទុះរត់មក ដល់ដែរ :

- ល្បងភោគ! ខ្ញុំសប្បាយចិត្តណាស់ដែលល្បងនៅរស់ ។

ភោគមិនឆ្លើយទេ ។ នាយក៏បោះការុងចុះទៅលើដីព្រួសហើយ ក៏ប្រាសដេកពីលើការុងនោះ ធ្មេចភ្នែកស្រមុកខុរភ្លាមលែងឮនរណា សួរសុខទុក្ខអ្វីទាំងអស់ ត្បិតនាយកំពុងតែស្រម័យឃើញនាងផ្សេាត អត់អាវហែលដេញកែងកិត១នៅឡើយ ។ ជាពិសេសទៅទៀតនោះ គឺនាងកំពុងមិចភ្នែកស៊ីញ៉ូដាក់នាយថែមទៀតផង បានជានាយមិន ចង់អោយដាច់ខ្សែរឿងទេ គិតតែពីខំធ្មេចស្រម័យតទៅទៀត ។

ព្រឹកស្អែកឡើង....

CHANBOKEO.COM
CHANBOKEO.COM

នាងប្រមូលភ្ញាក់ពីដំណេកមុនគេ ឃើញនាយភោគនៅស្រមុក នៅឡើយ ។ រីឯពីរនាក់ទៀតក៏នៅដេកហៀរទឹកមាត់មិនទាន់ភ្ញាក់ ម៉ាក់មួយដែរ ។ ពេលនោះ នាងកូរពោះគ្រូក១ ទឹកឃ្លានបាយណាស់ត្បិតអីកាលពីម្សិលមិញ បាយម៉ាកញ្ចប់ចែកគ្នាបួននាក់ ដូចជាវេទនាដល់សួរហើយ ។

- នែ៎! តាប៉ិ! ងើបឡើងមើស៏! ខ្ញុំហេវបាយណាស់!

- ហ្អាស់..?

- ខ្ញុំហេវបាយណាស់!

នាយភោគឮហើយក៏ភ្ញាក់ងើបអង្គុយឡើង :

- ខ្ញុំក៏ហេវដែរ តែមិនដឹងធ្វើម៉េចក៏ចេះតែសំងំដេកទៅ

- សួរពួកម៉ាកពីរនាក់នោះមើល៏ ក្រែងនៅសល់លុយខ្លះ...

- អត់មានទេ បងស្រីអើយ (រាសីងើបមុខមកហើយឆ្លើយរឹង)

- ខ្ញុំក៏អត់ដែរ... អោយថ្ងៃឡានពីម្សិលអស់ទៅហើយ (សំណាង ឮហើយ ស្រែកតបមកដែរ)

- អុញ! ភ្ញាក់ហើយហ្អែស? (នាងប្រមូលលាន់មាត់)

- ស្រេចហើយ! តើថ្ងៃនេះយើងមានអីល្បៀងក្រពះទៅ? (នាយ ភោគលាន់មាត់)

ស្រាប់តែនាងប្រមូលដាក់ភ្នែកទៅចំការុងស ដែលនាយភោគ រត់អោប រត់ពុន រត់លីម៉ាយប់មកហើយ ។ នាងក៏ឧទានថា:

- យី! តាប៉ិ! ហើយចុះ អាការុងសមួយនេះ វាមានស្អីដែរ នៅខាងក្នុង បានជាតាប៉ិឯងដេកយាមវាម្ល៉េះ?

នាយភោគបើកភ្នែកធំ១ ធ្វើអាការៈភ្ញាក់ផ្អើល :

- អុញ?មែនតើ ! បងមិនបានចាប់ភ្លឹកទេ គ្រាន់តែដឹងថាបាន ដណ្តើមការុងនេះមកពីចោរហើយក៏ធ្លាក់ទឹកទៅ ។ ដោយភ័យងាប់ ខ្លាំងពេក បងក៏ភ្លេចគិតទៅ ហើយក៏ចេះតែលីយកមកតាមខ្លួន តែអញ្ចឹងទៅ ណាំអូនប្រមូល ។

- អញ្ចឹងយើងស្រាយវាមើល៏ ក្រែងមានឥវ៉ាន់ល្អ១យកទៅលក់ បានលុយចាយ ។

នាយភោគក៏ទាញការុងមកស្រាយ ។ លុះលាត់មើលឃើញ ឥវ៉ាន់ខាងក្នុងហើយ ស្រាប់តែនាយបើកភ្នែកមូលក្លំដូចប្រាក់កាក់ ។ នាងប្រមូលនឹកងឿងឆ្ងល់ក៏ឈ្ងោកមើលដែរ ស្រាប់តែធ្វើភ្នែកមូលក្លំដូចគ្នា ។ ឃើញដូច្នោះ រាសីនិងសំណាងក៏ស្ទុះមកមើល ទង្គិច ក្បាលគ្នាទៀត រួចក៏ធ្វើភ្នែកមូលក្លំតាមដូចគ្នាទាំងអស់....

- មែនឬមិនមែន? (ភោគសួរ)

- ខ្ញុំថាមែន! (រាសីឆ្លើយ)

- សុទ្ធឬមិនសុទ្ធ ? (នាងប្រមូលសួរ)

- ខ្ញុំថាសុទ្ធ ! (សំណាងឆ្លើយ)

- លាភឬមិនលាភ? (ភោគសួរ)

- ខ្ញុំថាពិតជាលាភ! (នាងប្រមូលឆ្លើយ)

នាយភោគលូកដៃស្រវាលើកមួយដុំចេញមក..... ស្រាប់តែនាងប្រមូលស្រវាយកទុកវិញយ៉ាងរហ័សមើលមិនទាន់ :

- នែ៎ល្បង! ប្រយ័ត្នមានគេឃើញហើយមកប្លន់យកទៅវិញអស់ទៅ

- អញ្ចឹងយើងទៅកាយរាប់នៅឯណា? (នាយភោគសួរ)

នាងប្រមូលអេះក្បាលអង្គុយគិតម៉ាសន្ទុះទើបឆ្លើយឡើង :

- នៅក្នុងបង្គន់សាធារណៈ!

- យី! ម៉េចទៅរើសកន្លែងល្អម្លេះ? (នាយភោគសួរ)

- គឺកន្លែងដែលគ្មានគេសង្ស័យណា៎

ព្រមព្រៀងហើយ គេក៏នាំគ្នាទៅរកកន្លែងគួរសមសំរាប់ចាក់ការុងរាប់តវ៉ាន់ដែលគេយកបានពីចោរកាលពីយប់មិញ ។ ពីរនាក់ សំណាងនិងរាសីជាអ្នកឈរយាមនៅខាងក្រៅ ។ ចំណែកនាយភោគ និងប្រពន្ធជាអ្នករាប់ ។ លុះចេញមកពីកន្លែងគួរសមវិញ ស្រាប់តែសំណាងនិងរាសីឃើញប្តីប្រពន្ធទាំងពីរបញ្ចេញមុខរីករាយ ថ្លាបំព្រង ដូចកូនស្ទៃត្រូវភ្លៀងអញ្ចឹង ។ រាសីក៏ឈ្ងោកខ្សិបសួរ :

- មានអីខ្លះល្បង?

- មានតែដុល្លារតែខ្ទាស់ៗ... (នាយភោគឆ្លើយខ្សិបៗ)

ស្រាប់តែនាងប្រមូលចាប់អោបថើបថ្ពាល់នាយភោគលាន់ប៉ក់:

- ទាល់តែអញ្ចឹង ទើបសមជាប្តីរបស់អូនប្រមូលមែន!!

000000000000

CHANBOKEO.COM
CHANBOKEO.COM

## វគ្គទី៩
## ដំណើរស្វែងរកសំណាងនិងរាសី

ភោគនិងប្រពន្ធបានយកលុយទិញផ្ទះមួយល្វែង នៅជិតម្តុំពេទ្យ លោកសង្ឃ រកស៊ីលក់ចាបហួយ ។ តែអ្នកទាំងពីរក៏មិនភ្លេចមិត្ត ភក្តិកំសត់កម្រទាំងពីររូបរបស់គេទាំងពីរនោះដែរ ។ គេក៏ផ្គុងផ្តើមអោយអ្នកទាំងពីរមានមុខរបរឡើង ។ សំណាងប្រាប់ថា គេចង់ចូល ប្រលងស្រីស្រស់ប្រុសស្អាត ត្បិតគេជាបុរសមានរូបសង្ហារណាស់ ក្រែងបានធ្វើជាតារានៅផលិតកម្មណាមួយ ។ ចំណែកនាយរាសីវិញ មានចិត្តល្អគ្រាន់តែល្ងង់បន្តិច ហើយគេក៏មិនចង់ធ្វើអ្វីមានមុខ មាន មាត់ធំដុំទេ ។

សព្វថ្ងៃរាសី ធ្វើជាអ្នកជួយដឹកជញ្ជូនឥវ៉ាន់អោយនាយភោគនិង នាងប្រមូល បោះតាមរានក្នុងផ្សារនានាក្នុងក្រុងភ្នំពេញ ។ តាមពិត នាយយើងនៅតែមានចិត្ត មានអារម្មណ៍ភ័យងាប់មុនស្លាប់ដូចជា លោកតាហោរទាយទុកនោះណាស់ ។ ម្ង៉ៃៗនាយដេកបន់កុំអោយនាយសំណាងបាក់ចិត្តស្រលាញ់ស្រីណាសោះឡើយ ត្បិតអីបើគេ រៀបការផ្សំដំណេកកាលណា នាយក៏អស់សិទ្ធិរស់នៅលើលោក នេះតទៅទៀតដែរ ។

ថ្ងៃនេះ រាសីធ្វើការហើយតាំងពីថ្ងៃ នឹកអផ្សុកពេក ក៏ទៅ អង្គុយលេងមាត់ទន្លេលំហែកាយ ។ ប៉ុន្តែទោះជានាយមានចិត្តវិល វល់បារម្ភខ្លាចងាប់យ៉ាងណា ក៏មិនស្រេកស្រុតសាច់ឈាមដែរ ត្បិតអីតាំងពីបានមករស់នៅទីក្រុងធ្វើការហត់មក នាយយើងទទួលទាន អាហារឆ្ងាញ់ៗបរិបូណ៌ទៀតផង ម្យ៉ាងដោយសារនាយភោគនិង នាងប្រមូលគេរកស៊ីកាក់កបផង ម្ល៉ោះហើយគេបំប៉នរូបនាយមិនដែលអោយនាយខ្វះស៊ីខ្វះចុកទេ ។ ចំណែកលុយចាយ ក៏នាងប្រមូល នាយភោគហុចអោយចាយយ៉ាងបរិបូណ៌ គ្រាន់តែនាយមិនព្រម ទទួលយកកំរៃប្រចាំខែពីអ្នកទាំងពីរឡើយ ព្រោះនាយគិតថាខ្លួនជា មនុស្សគ្មានអនាគត

CHANBOKEO.COM
CHANBOKEO.COM

មិនដឹងត្រូវស្លាប់ថ្ងៃណា ម្ល៉ោះហើយ ក៏មិនខ្ចី វីរវល់ នឹកចង់មានចង់បាន ឬចង់ល្បីឈ្មោះដូចជាសំណាង មិត្ត របស់ខ្លួនឡើយ ។

ខ្យល់បក់រំភើយពីទន្លេ.... រាសីទិញអំពៅសាងអង្គុយខំទំពារ មួយៗ សំលឹងទៅផ្ទៃទឹកទន្លេខែប្រាំងថ្លាយង់ស្មើរយល់បាតដី... ក្នុង ចិត្តមមៃគិតវិលវល់ផ្តេសផ្តាស ស្រាប់តែនាយដាក់ភ្នែកក្រលេកទៅ ម្នាងឃើញដូនចាស់មួយរូប កំពុងលោតទំលាក់ខ្លួនពីច្រាំងចំណោត មួយទៅក្នុងទន្លេ ។ នាយឃើញហើយស្រែកភ្លាត់មាត់ថា :

- យាយ! យាយ! ជួយផង! ដូនចាស់លោតទឹកសំលាប់ខ្លួនហើយ ។

រាសីមិនបានគិតអ្វីច្រើនទេ គ្រាន់តែថាចប់ ក៏ស្ទុះលោតចុះទៅ តាមពីក្រោយភ្លាម ។ ការពិត នាយក៏មិនសូវជាពូកែហែលទឹកដែរ ទំរាំហែលស្រវាចាប់ខ្លួនដូនចាស់បានជាប់ នាយក៏ឈ្លក់ទឹកខ្លួនឯងរិះ តែដាច់ខ្យល់ម្តងៗ ។ លុះនាយហែលយកដូនចាស់មកជិតដល់ច្រាំង ទើបមានមនុស្សពីរបីនាក់ទៀតចុះមកជួយតាមក្រោយ ។ រាសីដង្ហក់ ខ្យល់កខក់តែម្នាក់ឯង ។ អ្នកស្រុកក៏នាំគ្នាជួយរលាក់ទឹកអោយ ដូនចាស់ដឹងខ្លួនមកវិញ ។ សំណាងល្អ គាត់ក៏ដឹងខ្លួនម្តងទៀតមែន ។ អ្នកស្រុកម្នាក់សួរថា :

- យាយមានក្រុមគ្រួសារនៅទីណាទេ? ចាំពួកយើងជូនទៅ...

យាយចាស់ក៏ពោលឡើងខ្សាវៗ :

- អត់មានទេ...! កូនៗគេស្លាប់ចោលអស់ នៅតែចៅប្រុសមួយ ។ ឥលូវវារត់ចោលយាយ ទៅតាមសង្សារនៅខេត្តក្រៅយូរខែហើយ មិនដែលឃើញមកផ្ទះទេ ។ ពេលនេះ យាយអត់លុយទិញស្បៀង គ្មានអ្វីចិញ្ចឹមពោះបានជា...

រាសីឮដូច្នោះ ក៏នឹកអាណិតដូនចាស់ក្នុងចិត្តគ្រលួច នឹកដល់ខ្លួន ឯងដែលមានជីវិតកំព្រា ហើយធ្លាប់ដាច់អាហារដាច់ស្បៀងជាញយ ដងក្នុងជីវិតរបស់គេ ។ នាយក៏ស្រវាលូកក្នុងហោប៉ៅបានប្រាក់ ១០ ដុល្លារ ក៏ហុចជូនទៅដូនចាស់នោះ :

- យាយ! ខ្ញុំជូនលុយនេះទៅយាយចុះ ។ ខ្ញុំក៏ជាអ្នកក្រ រកស៊ី ម៉ាងៃរស់ម៉ាងៃដែរ ។ តែយាយអើយ! ជីវិតមនុស្សមានតំលៃណាស់ យាយកុំធ្វើអត្តឃាតអី ព្រះលោកប្រោសយើងមិនរួចទេ ។ ឥលូវនេះ យាយសុខចិត្តទៅនៅវត្តទេ? ចាំខ្ញុំទៅសុំលោកចៅអធិការវត្តឱ្យ យាយនៅស្នាក់សុំធមិប្រសើរជាជាងណាំយាយ ។

ឮសុជាតិពោលដូច្នោះ ដូនចាស់ស្រក់ទឹកភ្នែកច្រោកៗ ហើយក៏ មានប្រសាសន៍តបវិញថា :

CHANBOKEO.COM
CHANBOKEO.COM

- អានាងអើយ! ឯងមិនមែនជាសាច់ឈាមរបស់យាយផង ហេតុអី ក៏ឯងចេះគិតគូរសុខទុក្ខរបស់យាយដល់ម្លឹង? ចុះហេតុអីចៅរបស់ យាយបង្កើតបែរជាគ្មានចិត្តអាណិតយាយអីបន្តិចសោះទៅវិញ?

ឃើញជូនចាស់ស្ថិតក្នុងទុក្ខសោក រាសីក៏សាកសួរអ្នកស្រុក រក ផ្លូវជូនយាយទៅវត្តណាដែលនៅជិតទីនោះជាងគេ ហើយក៏ហៅ ស៊ីក្លូដឹកគាត់ចេញទៅ ។ អ្នកស្រុកក៏នៅឈរមើលរហង់ពីក្រោយ សំដែងការរីករាយ ដោយឃើញរាសីមានទឹកចិត្តជួយមនុស្សចាស់ រងគ្រោះនោះ ។

ល្ងាចបន្តិច រាសីក៏ត្រលប់មកដល់ផ្ទះវិញ ស្រាប់តែនាយឃើញ សំណាងមកដល់ដែរ ថែមទាំងមានទឹកមុខញញឹមញញែមយ៉ាង ចំលែកតែម្តង:

- អឺ! សំណាង! ថ្ងៃនេះអីក៏ រីករាយម្ល៉េះ? កុំប្រាប់ណាថា កំពុងតែ លួចស្រលាញ់កូនក្រមុំគេ....

- អូហ៍ អត់ទេ ល្បងរាសីអើយ! ការពិតខ្ញុំមានឈ្មោះចូលប្រលង ក្នុងកម្មវិធីស្រីស្រស់ប្រុសស្អាតនៅវេលាស្អែកនេះហើយ ។

CHANBOKEO.COM

- អីយ៉ា! គ្នាជួយត្រេកអរផងណា៎! ក្តីស្រម័យរបស់ឯងកំពុងតែ ឈានទៅរកក្តីសំរេចហើយ ។

នាយភោគនិងនាងប្រមូលក៏សប្បាយចិត្តមិនស្ទើរដែរ កាលបើ ដឹងថា សំណាងមានឱកាសបានស្គាល់វេទិកាធំដុំនឹងគេ ។ ភោគក៏ ពោលឡើង:

- គិតទៅ ជោគជតាមនុស្ស មើលមិនឃើញមែន.... ប្រហែល បន្តិចទៀត សំណាងបានក្លាយជាតារាល្បីឈ្មោះមិនខាន ។

CHANBOKEO . COM

គេទាំងបួននាក់បានជប់លៀងអាហារយ៉ាងឆ្ងាញ់ ជូនពរមិត្តគូកនដែលត្រូវឡើងវេទិកា នារសៀលថ្ងៃស្អែកនេះ ។

រាត្រីនោះ សំណាងគេងមិនលក់ទេ ប្រែខ្លួនទៅមកៗមួយយប់ ទល់ភ្លឺ ។ ចំណែករាសីវិញ ជាមនុស្សដេកភ័យមុន ងាប់ម៉ាអាយ៉ូស ទៅហើយ យប់ណាក៏មិនដែលផ្ទេចពេញដំណេកទេ ខុសអ្វីតែនាយ ភោគនិងនាងប្រមូលប៉ុណ្ណោះ ដែលនាំគ្នាធ្វើដំណើរទៅកេះមេឃ រាប់ផ្កាយ រាល់យប់ មិនដែលចុះដីម្តងណាឡើយ ។

រសៀលស្អែកឡើង....

នៅលើវេទិកាប្រកួត...

សំណាងស្លៀកពាក់យ៉ាងសង្ហារ សមនឹងការហ្វឹកហ្វឺនដំណើរ យ៉ាងហំហួន រួមជាមួយនឹងភាពញញឹមលើផ្ទៃមុខដ៏ស្អាតរបស់នាយ យ៉ាងបំព្រងទៀតនោះ ទស្សនិកជនទាំងឡាយ រួមទាំងគណមេប្រយោគផង មានការពេញចិត្តពេញថ្លើមខ្លាំងសំបើមណាស់ ។ ស្នូរ ទះដៃលាន់រំពងខ្ទរសាលប្រកួត ។ រាសីក្តី

នាយភោគនិងប្រពន្ធក្ដី ក៏អង្គុយមិនជាប់គូថនឹងកៅអីដែរ ។ គេហ៊ោរផង ទះដៃផង កញ្ជ្រៀវអឺងកង ដើម្បីសំដែងការលើកទឹកចិត្តចំពោះមិត្តរបស់ខ្លួន ។ វេនប្រកាសលទ្ធផលក៏ចូលមកដល់ :

- បេក្ខជនដែលជាប់លេខពីរ ប្រចាំកម្មវិធីនារាត្រីនេះ សូមជូនដល់ បេក្ខជនដែលមានឈ្មោះ សំណាង មកពីខេត្របាត់ដំបង ។

ស្នូរហ៊ោរកញ្ជ្រៀវ ក៏បានលាន់ឮឡើងសាជាថ្មីម្ដងទៀត ។ ទាំង រាសី ទាំងនាយភោគនិងនាងប្រមូល ស្រែកហ៊ោរឡើងខ្ទររោង....

ពិធីប្រកួតចប់ហើយ....

នៅខាងក្រៅសាលប្រកួត ក្លើទាំងបីរួមទាំងនាងប្រមូលក៏នាំគ្នា ថតរូបទាំងអស់គ្នាជាមួយសំណាង តារារះថ្មីក្នុងកម្មវិធីស្រីស្រស់ ប្រុសស្អាតយ៉ាងសែនសប្បាយរីករាយក្រៃលែង ។ ពេលនោះ នាយសំណាងមានអារម្មណ៍ថា ខ្លួននាយស្រាលដូចសំឡី ដើរអណ្ដែត១ផុត ពីដី.. ចំលែកយ៉ាងណាមិនដឹងទេ ត្បិតនាយមិននឹកស្មានថា បុរស កំលោះដាច់ៃយ៉ៃម៉ៃណោះសោះ ស្រាប់តែមានវាសនាមកក្លាយជា តារាជាប់រូប ជាប់នាមល្បីនឹងគេម្នាក់នៅភ្នំពេញដែរ ។ នាយបានថត រូបយ៉ាងច្រើនជាមួយរាសី នាយភោគ និងនាងប្រមូល ។ បន្តិចមក អ្នកទាំងបីក៏ ត្រលប់ទៅផ្ទះមុនបាត់ទៅ ទុកអោយសំណាងនៅជួប និយាយជាមួយនឹងលោកចាងហ្វាងខ្សែភាពយន្ត ដែលកំពុងចង់ ពិគ្រោះរឿងកុងត្រាថតកុនថ្មីជាមួយនឹងសំណាង ទើបនាយមិនអាច ត្រលប់ទៅផ្ទះ ព្រមជាមួយគ្នាទាំងបួននាក់បាន ។

នៅក្នុងបន្ទប់ដែលសំណាងអង្គុយរង់ចាំជួបលោកចាងហ្វាង... សំណាងអង្គុយ អរផង ភ័យផង នៅតែម្នាក់ឯង ។ រំពេចនោះ ស្រាប់តែលោកចាងហ្វាងនាំនារីរូបស្អាតសោភាមួយរូប ចូលមកដល់ ដែរ ។ គ្រាន់តែដាក់ភ្នែកក្រលេកឃើញនាងភ្លាមកាលណា សំណាង សំលឹងនាងភ្លឹកយ៉ាងចំហមាត់ធ្លុង លង់ចេតនារម្មណ៍លើរូបសោភ័ណ របស់នាងពន់ពេកក្រៃ ។ លោកសេដ្ឋាដែលជាចាងហ្វាងក៏ណែនាំអ្នក ទាំងពីរអោយស្គាល់គ្នា :

- សួស្ដី! សំណាង! នេះនាងកញ្ញាផល្លា តារារូបស្រស់ដែលជាប់ លេខមួយក្នុងកម្មវិធីរបស់យើងកាលពីខែមុន ។

រួចហើយលោកសេដ្ឋាក៏បែរទៅកញ្ញាផល្លាហើយក៏ណែនាំដែរ :

- កញ្ញាផល្លា! នេះគឺលោកសំណាង តារាថ្មីមួយក្នុងចំណោមបីរូប ដែលយើងជ្រើសរើសជាប់នៅរាត្រីនេះ ។

មាណវីសោភាក៏ផ្ដុំដៃលំទោនចំពោះសំណាង ដែលកំពុងសំលឹង រូបនាងមិនដាក់ភ្នែកសោះ ។ នៅក្នុងចិត្ត សំណាងលួចគិតថា :

CHANBOKEO.COM

- ពុទ្ធោ! អីក៏ស្រស់ស្អាតម្ល៉េះហ្ន៎? បើសិនជានាងក្លាយជាគូព្រេង របស់ខ្ញុំ ម្ល៉េះសមជីវិតរបស់ខ្ញុំនេះ មានន័យជ្រាលជ្រៅជំរៅដូច សមុទ្ទមិនខានទេ។

លោកសេដ្ឋាក៏ចាប់ផ្ដើមនិយាយ ពីផែនការថតខ្សែភាពយន្ត ដែលមានអ្នកទាំងពីរជាតួឯកនៅក្នុងរឿង។



សំណើនេះបានធ្វើឱ្យ សំណាងរីកមុខប៉ុនដញ្ជាំងព្រះវិហារ អរហើបគួចពីកៅអីរហូតលែង នឹកនាចង់បានប្រាក់បំណាច់អ្វីពីការថតកុននោះហើយ ក្រៅតែពីចង់ ដើរតួឯកជាមួយស្រីស្រស់តែម្យ៉ាងប៉ុណ្ណោះ។ កញ្ញារូបស្រស់ក៏មាន កិរិយាទំនងដូចជារអៀស១ខ្លួនបន្តិចដែរ កាលបើឃើញសំណាង បញ្ចេញអកប្បកិរិយានិងឫកពា ហាក់ដូចជាចាប់អារម្មណ៍មកលើរូប នាងយ៉ាងខ្លាំងដូច្នោះ។

រាត្រីនោះ សំណាងគេងមិនលក់សោះ មួយយប់ទល់ភ្លឺ។ គេ ដេកស្រម័យឃើញតែរង្វង់ភក្ត្ររបស់នារីរូបស្អាត ឈ្មោះផល្លានោះ ឥតឈប់ឈរសោះឡើយ។ លុះឃើញ នាយយើងដេកប្រែប្រួល រមួលរម៉ាត់តែម្នាក់ឯងនៅលើគ្រែ រាសីក៏បើកភ្លើងហើយប្រែខ្លួន សួរថា :

- សំណាង! វាថីហ្នឹង? អន្ទះសាដូចមនុស្សចង់បានប្រពន្ធម្លេះ?

- យី! ល្បងរាសីឯងហ្នឹងក៏ប៉ិនទាយដល់សួរហើយ ដូចមើលឃើញ!

- អូហ៎?... មែនហ្ន៎ស?

រាសីបើកភ្នែកធំៗ ស្ទុះក្រោកយ៉ាងរហ័ស ហើយសួរទៀតថា :

- នេះល្បងឯងកំពុងមានស្នេហាឬ?

- ហ៉ាំសៗ... ខ្ញុំគិតថាប្រហែលជាអញ្ចឹងហើយ...

- ពុទ្ធោ!.... តើនាងជានរណាដែរទៅ?

- នាងឈ្មោះផល្លា ជាតួឯកស្រីក្នុងរឿងដែលខ្ញុំបំរុងចេញថតនៅថ្ងៃ ស្អែកនេះ ។

រាសីប្រាសខ្លួនលើគ្រែវិញ សំដែងអាការៈអស់សង្ឃឹម ។

- ល្បងឯង.... ម៉េចមិនជួយអរពួកម៉ាកអញ្ចឹង?

- ជួយអរអីរួចលោកអើយ? ល្បងឯងមិនចាំទេហ៎? កាលនោះ លោកតាហោរនៅបាត់ដំបងទាយអោយខ្ញុំថា ពេលណាសំណាងឯង

បានរៀបការ ខ្ញុំនេះនឹងត្រូវដេកងាប់នោះអី... ហ៊ឺ!

រាសីយកដៃគងថ្ងាសធ្វើមុខស្អុយប៉ែ ។ សំណាងក៏និយាយកម្សា ចិត្តមិត្តថា :

- ហ្អើយ! កុំទៅព្រួយ ទៅខ្វល់ធ្វើអ្វី ណាំល្បង! មើលតែខ្ញុំចុះ.........

លោកតាទាយឱ្យ ថាខ្ញុំនឹងបាននាងក្រមុំរែកពោតស្ងោរលក់ជាគូ ។ តែឥលូវនេះ ខ្ញុំមករស់នៅ ភ្នំពេញមានមុខមាត់កាន់តែល្បី... រឿងអីដែលខ្ញុំទៅរៀបការជាមួយនាងរែកពោតស្ងោរលក់ជាគូនោះ កើត? ពិតជាទៅមិនរួចឡើយ ។ ខ្ញុំមិនជឿជើងលេខដែលលោកតា មួយរូបនោះទាយអោយខ្ញុំទេ ។ ចំណែកល្បងវិញ ក៏មិនងាយ ស្លាប់ទៅណាចោលខ្ញុំដែរណាំ...

ទោះជាយ៉ាងណាក៏រាសីនៅតែខ្វាយខ្វល់ដដែល ។

នៅរាត្រីនោះ សំណាងប្រែខ្លួនរសាប់រសល់ស្រម័យនឹកទៅ កញ្ញាផល្លាដ៏សោភាមិនឈប់ឈរ ហើយក៏លើកដៃទូលសំពះ បន់សុំអោយបានជួបស្រីស្រស់ប្រិមប្រិយជាគូគ្រង់ ។ ផ្ទុយទៅវិញ រាសីរសាប់រសល់ប្រែទៅប្រែមក បន់សុំអោយអ្វីដែលលោកតា ទាយរួចហើយនោះជា ការវាយជើងលេខច្រលំទាំងអស់ ។

0000000000000

000

CHANBOKEO.COM
CHANBOKEO.COM

វគ្គទី៦

ហេតុតែគូ

ថ្ងៃនេះ រាសីអង្គុយធ្វើមុខជូរហួញ មិនព្រមចេញទៅណាទេ។ ប្លែកអីតែសំណាងដែលតែងខ្លួនយ៉ាងហ៊ឺហា ដើរហួច លួចច្រៀងរងំ តែម្នាក់ឯងនៅមុខកញ្ចក់ឆ្លុះ ៖

- ឱ! ផល្លាកញ្ញារូបស្រស់គូនឹងកំលោះបងអើយ! ថ្ងៃនេះ បងនឹង បានជួបអូនសាជាថ្មីហើយ... ព្រះអើយ! សប្បាយចិត្តអ្វីម្ល៉េះទេខ្ញុំ! សក្រវ៉ាទិ ឱណាផ្កា ចំប៉ី បងស្រលាញ់ស្រី អស់ពីដួងចិត្ត.... សក្រវ៉ាទិ ឱណាផ្កាព្រលិត បងស្នេហ៍វរមិត្រ ជីវិតផ្ញើដៃអូន....

- នែ៎! ឈប់ច្រៀង! ឈប់ហួចមើល៍ សំណាង!!

- យ៉ាងម៉េចហ្នឹង ល្បួងរាសី? រាល់ថ្ងៃ ល្បួងឯងតែងតែតឿន អោយខ្ញុំច្រៀងអោយស្តាប់

ចុះថ្ងៃនេះហេតុអីបានជាតឿនអោយ

ឈប់ទៅវិញ? បទមួយនេះ ពិរោះណាស់ណា៎ ល្បួង....!

- បទហ្នឹងជាបទលួងលោមដួងចិត្តល្បួងឯងមែន... តែវាជាបទខ្លង ខែកសំរាប់រូបខ្ញុំណា៎...

- ពុទ្ធោ! រាសី! ល្បួងឯងទៅគិតស្មឹរវែងឆ្ងាយម្ល៉េះ? នែ៎... បើល្បួង ភ័យខ្លាចងាប់ណាស់...

ល្មមទៅវត្តនិមន្តលោកអោយស្រោចទឹក ជំរះរាសីមិនល្អនោះចោលទៅ។

ថាហើយ សំណាងក៏ដើរចេញទៅ ត្បិតត្រូវទៅហ្វឹកហ្វឺនធ្វើការ ថតកុនថ្ងៃដំបូង។ រាសីសំលឹងតាមសំណាងហើយក៏ក្រោកក្រេះ ជិះ ម៉ូតូទៅតាមពីក្រោយសំណាងដែរ។ ថ្ងៃនោះ សំណាងទឹកឆ្ងល់ ណាស់ ដែលរាសីដើរតាមនាយរហូត ។ នាយក៏លួចសួរថា ៖

- នែ៎ ល្បួងឯងកំពុងធ្វើអីហ្នឹង តាមពីក្រោយខ្ញុំអោយស្អិត?

- ចង់ធ្វើជាអង្គរក្សអោយល្បួងឯងណា... បានធ្វើការជាតារាហើយ ត្រូវតែមានមនុស្សតាមបំរើ ទើបវាសម...

CHANBOKEO.COM
CHANBOKEO .COM

- យី! ... និយាយដូចត្រូវ... ថ្ងៃនេះល្បងឯងផឹកថ្នាំអី បាននិយាយ ដូចជា មានន័យគួរអោយស្តាប់យ៉ាងនេះ?

សំណាងគេស៊ីជោរណាស់ កាលបើរាសីស្មគ្រ័មកតាមបំរើនាយ ជាអង្គរក្ស ។

លុះសំណាងចូលជួបចាងហ្វាងខាងហ៊ឹកហ៊ឺនបាត់ទៅ រាសីក៏លួចស្កាត់ ទៅរកកញ្ញារូបស្រស់ឈ្មោះផល្លានោះភ្លាម :

- ជំរាបសួរអ្នកនាងផល្លា!

- ព្រះអើយ! តើអ្នកជានរណាដែរ ហេតុអ្វីក៏ស្គាល់ឈ្មោះខ្ញុំ?

- ហែសៗ! គឺពួកម៉ាករបស់ខ្ញុំគេប្រាប់...

- អូហ៍! តើពួកម៉ាករបស់អ្នក ជានរណាដែរទៅ?

- គឺជាតួឯកប្រុស ដែលកំពុងហាត់ហ៊ឹកហ៊ឺននោះអី...

- លោកសំណាងមែនទេហ៍?

- មែនហើយបាទ!

- ហើយចុះអ្នកមកជួបខ្ញុំមានការអ្វីដែរ?

រាសីឮនាងសួរដូច្នោះ ក៏ឈរអេះអុញ មួយស្របក់ទើបដាច់ចិត្ត ឆ្លើយទៅវិញថា:

- គឺថា... ខ្ញុំមកជំរាបសុំអ្នកនាងរឿងមួយ...

- រឿងអ្វីទៅចាស?

- គឺ... គឺ... ថា... បើប្រសិនជាសំណាង មិត្តរបស់ខ្ញុំគេមកនិយាយសុំ ស្នេហ៍ពី អ្នកនាង... សូម.. អ្នកនាងកុំយល់ព្រមអោយសោះ...

- ពុទ្ធោ! ខ្ញុំទើបស្គាល់លោកសំណាងពីម្សិលមិញទេ... រឿងបញ្ហា ស្នេហា មើលទៅមិនទាន់អាចមានផ្លូវនិយាយគ្នាកើតនៅឡើយទេ..

- តែគេនិយាយរំលឹកពីអ្នកនាងមិនដាច់ពីមាត់សោះ..

- ថាម៉េច?.... អូហ៍! ខ្ញុំដឹងហើយ..... ការពិតអ្នកកំពុងតែកើតរោគ ប្រចណ្ឌលោកសំណាងហើយខ្លាចលោកសំណាងមកញ៉ែខ្ញុំ តើមែន ទេហ៍? យឺ! ខ្ញុំមិនដឹងសោះថាអ្នកជាសង្សាររបស់លោកសំណាង... អរគុណណាស់ដែលបានប្រាប់ខ្ញុំអោយបានដឹងមុនថា លោកសំណាង និងរូបអ្នកជាបុរសខ្ទើយ...

- គឺ... អត់ទេ! អ្នកនាងយល់ច្រលំហើយ... គឺថា... គឺថា...

- បើមិនមែន... តើយ៉ាងម៉េចវិញ?

CHANBOKEO.COM
CHANBOKEO . COM



- គឺខ្ញុំនិងសំណាងមិនមែនប៉េដេទេ ប៉ាទ! តែ ខ្ញុំមកនេះ ចង់ជំរាបថា សូមកុំអោយអ្នកនាងឈ្លក់លង់ស្នេហ៍ នឹងសំដីសំណាងអោយសោះ ត្បិតអីគេមានគូព្រេងប្រចាំជីវិតរបស់គេរួចហើយ... . ដែលនៅរង់ចាំ រូបគេឯខែត្របាត់ដំបងឯណោះ ។

រាសីនិយាយផង លេបទឹកមាត់ផ្សើមបំពង់កផង ត្បិតនាយកំពុងខំរកនឹកមធ្យោបាយយ៉ាងណារារាំងកុំអោយសំណាងមានឱកាសស្រលាញ់ស្រីហើយរៀបការបាន ។ ភ្លាមនោះ កញ្ញាផល្លាទឹក សង្ស័យណាស់ ក៏សួរថែមទៀតថា :

- ហើយចុះ.... គូប្រចាំជីវិតរបស់លោកសំណាងជានារីណាដែរ? តើអ្នកអាចប្រាប់ខ្ញុំបានដែរទេហ៏...

- គឺ... ខ្ញុំ... មិនស្គាល់នាងទេ...

- ហ្អ៎ក? បើមិនស្គាល់  ម៉េចក៏ដឹងថា នាងជាគូប្រចាំជីវិតរបស់គេ?

- ប៉ាទ... គឺ... មានន័យថា... ខ្ញុំមិនស្គាល់ឈ្មោះនាងទេ គ្រាន់តែដឹង ថានាងជាក្រមុំលក់ពោតស្ងោរ...

- ចា៎ស? ថាម៉េច? នាងក្រមុំលក់ពោតស្ងោរ?

ស្រាប់តែកញ្ញាផល្លាលាន់មាត់សើចខឹក១ យ៉ាងខ្លាំងចំលែកតែ ម្តង រួចហើយនាងក៏និយាយទៅកាន់រាសីថែមទៀតថា :

- អ្នកអើយ! ទៅផ្ទះ ពិសារបាយពិសារទឹក ហើយសំរាន្តអោយ ឆ្អែតសិនទៅ... មើលទៅ! អ្នកដូចជាមនុស្សអត់ងងុយណាស់ បាន ជាមកនិយាយរឿងកំប្លែងៗ បែបនេះ...

វំពេចនោះ សំណាងក៏លេចធ្លោមកដល់ :

- សួស្តី អ្នកនាងផល្លា! ហើយចុះកំពុងនិយាយអ្វីជាមួយរាសីមិត្ត របស់ខ្ញុំហ្នឹង? ឃើញសើចយ៉ាងស្រស់តែម្តង!

កញ្ញាផល្លាញញឹមហើយឆ្លើយវិញ :

- មិត្តរបស់លោកកំពុងប្រចណ្ឌ័រូបលោកដាក់ខ្ញុំហីយ...

ថាហើយ ធិតារូបស្រស់ក៏បោះជំហានចេញទៅ ។ សំណាង ក៏រត់តាមពីក្រោយ :

- ពុទ្ធោ! អ្នកនាង! អ្នកនាង... កុំយល់ច្រលំអី... ខ្ញុំនិងរាសីមិនមែន ជាអ្វីនឹងគ្នាដូចអ្នកនាងយល់ច្រលំទេ...

តែស្រីស្រស់ដើរចូលបន្ទប់បិទទ្វារបាត់ទៅ មិនព្រមនៅជជែក ជាមួយនាយឡើយ ។ សំណាងខឹងនឹងរាសីណាស់ ក៏ស្ទុះមកសួរថា :

CHANBOKEO.COM

- ល្បងឯងនិយាយស្អីខ្លះអំពីខ្ញុំប្រាប់ទៅគេហ៎?

- គឺ... គ្រាន់តែនិយាយថា...

- ថាយ៉ាងម៉េច?

- ថា... ថា.... សំណាងឯងដេកមមើហៅរកសង្សារទាល់ភ្លឺ...

- ហើយមានប្រាប់គេទេ ថាខ្ញុំមមើហៅឈ្មោះស្រីណា?

- អត់បានប្រាប់ផង...

- ហើយចុះម៉េចមិនជួយប្រាប់ផងថា បេះដូងរបស់ខ្ញុំកំពុងមមើរក នារីឈ្មោះផល្លាដ៏ប្រិមប្រិយ?

- ខ្ញុំភ្លេច...

- យ៉ាប់មែនល្បងឯងនេះ ។ ហើយចុះមាននិយាយអីប្រាប់នាងខ្លះ ទៀតទេ?

- បាទ... មាន...

- ហើយប្រាប់ថាម៉េចទៀតទៅ?

- ប្រាប់ថា... ល្បងឯងមានគូប្រចាំជីវិតរួចហើយ...

- អីយ៉ា! គ្រាន់បើ.. ចេះនិយាយចាក់ផាអោយនាងរំភើបចិត្តចំពោះ ខ្ញុំ... ហើយចុះល្បងមានប្រាប់នាងទេហ៎ ថាគូប្រចាំជីវិតរបស់ខ្ញុំជា រូបនាង?

- អត់ផង.... ខ្ញុំគ្រាន់តែប្រាប់ថា គូប្រចាំជីវិតរបស់ល្បងឯង គឺនារីលក់ពោតស្ងោរនៅបាត់ដំបង..

- ពុទ្ធោ! ភ្លៀងផ្គរ! ជន់ទឹកអូរ អស់ភូមិខ្ទេចខ្ទីរហើយជាន់នេះ...!!

រាសីឃើញសំណាងខឹងនឹងរូបនាយ មុខឡើងក្រហមឆេះ ក៏ដាក់ មេផាយប្រុយលែងមើលក្រោយតែម្តង។ គេមិនហ៊ានត្រលប់ទៅ ផ្ទះវិញទេ... ខ្លាចសំណាងរករឿង ក៏រត់គេចខ្លួនទៅកន្លែងផ្សេង មួយស្របក់សិន ក្រែងលោសំណាងគេត្រជាក់ចិត្តមកវិញ។ ដើរចុះ ដើរឡើងមិនដឹងទៅណា ក៏នឹកភ្នកដល់ដូនចាស់ដែលគេបានសង្គ្រោះ យកទៅផ្ញើនៅវត្តកាលពីថ្ងៃមុន... នាយក៏ចូលទៅលេង។

- អានាងអើយ! ទៅណាមកណាមានយួរផ្លែឈើមកផង?

- បាទ! ខ្ញុំទិញផ្លែស្វាយទុំយកមកផ្ញើយាយពិសារ។

- អឺ! អរគុណណាស់អានាងអើយ ដែលចេះនឹកឃើញដល់យាយ... យាយ ក៏សូមជូនពរដល់ចៅដែរ អោយឯងអាយុវែង...

ថាហើយដូនចាស់ក៏លើកដៃផ្ទុំឡើង។ រាសីក៏ប្រណម្យទទួលពរ ពីគាត់មកវិញដែរ :

- បាទ! អរគុណយាយ... ចុះយាយសព្វថ្ងៃរស់នៅក្នុងវត្តយ៉ាង ម៉េចយ៉ាងម៉ាដែរបាទ?

- ចិត្តយាយបានស្ងប់បន្តិចហើយ តាំងពីបានមកជ្រកកោនក្រោម ម្លប់ព្រះធម៌មក។ អរគុណចៅឯងច្រើនណាស់ដែលនាំអោយយាយ ឱ្យមកស្គាល់សេចក្តីសុខក្នុងចិត្តមកវិញ! ឯងពិតជាក្មេងប្រពៃមែន។

រាសីបានឮដូនចាស់មានប្រសាសន៍យ៉ាងនេះ ក៏សប្បាយរីករាយ ក្នុងចិត្ត ហើយក៏ភ្លេចព្រួយភ្លេចភ័យអស់រលីង។ យប់នេះ ដូនចាស់ បបួលអោយនាយស្នាក់នៅមួយយប់ ត្បិតមានគេធ្វើបុណ្យនៅវត្ត ត្រូវការដៃជើងជួយរៀបចំកិច្ចការក្នុងវត្ត។ ដោយហេតុថា នាយ កំពុងតែគេចមុខពីសំណាងផង រាសីក៏ស្ម័គ្រនៅបំរើវត្តមួយថ្ងៃទៅ។

ធ្វើបុណ្យចប់រួចដៃកាលណា កំលោះរាសីក៏យាត្រាត្រលប់ទៅ ផ្ទះវិញទាំងអារម្មណ៍ រីករាយខុសធម្មតា។ លុះនាយទៅដល់មុខផ្ទះ ស្រាប់តែរាសីប្រទះនឹងភោគដែលកំពុងតែងខ្លួនហ៊ឺហា បំរុងនាំនាង ប្រមូលជាប្រពន្ធចេញទៅណាមិនដឹង។ នាយក៏លាន់មាត់សួរថា :

- អីយ៉ា! ល្បងភោគ បងស្រីប្រមូល! ហើយចុះតែងខ្លួនស្អាតម្លឹង គិតនាំគ្នាទៅណាហ្នឹង?

- អូហ៎! រាសី! ស្លាប់ហើយ! យើងនាំគ្នាដើររកឯងរិះដាច់ខ្យល់ ស្លាប់។ ដឹងទេហ៎? យើងនេះកំពុងធ្វើដំណើរចេញទៅដណ្តឹង កូនក្រមុំគេ...

CHANBOKEO.COM

- ដណ្ដឹងកូនគេ? ដណ្ដឹងអ្នកណាអោយអ្នកណាទៅល្បង? កុំប្រាប់ ណាថាល្បងចង់រកប្រពន្ធអោយខ្ញុំ...

ខ្ញុំមិនទាន់នឹកចង់បានប្រពន្ធ នៅឡើយទេ!

- នរណាថា យើងទៅដណ្ដឹងប្រពន្ធអោយឯងនោះ?

- ចុម.....! បើមិនដណ្ដឹងអោយខ្ញុំ តើល្បងទៅដណ្ដឹងអោយអ្នកណា

ទៅវិញ?

- គឺ....ដណ្ដឹងអោយ....

- ពុទ្ធោ! ព្រះជាម្ចាស់! ឬក៏ល្បងកំពុងតែធ្វើជាចៅមហាឱ្យល្បង សំណាង?

- មែនហើយ! រាសីទាយចំប៉ក់តែម្ដង!

- ងាប់បាត់ហើយ អាវ៉ាអើយ...

CHANBOKEO.COM

រាសីលាន់មាត់ហើយយកដៃទះក្បាល រួចនិយាយបន្តទៀតថា:

- តែប៉ុណ្ណេះ អាវ៉ាតែស៊ីវឆាប់ៗនេះហើយមើលទៅ!!

- នែ៎ះ! ល្មមទៅផ្លាស់សំលៀកបំពាក់មក៏ ឆាប់ទៅចូលរួមពិធី នឹងគេ... ជិតដល់ម៉ោងហើយណ៎! (នាងប្រមូលបបួល)

រាសីនៅអេះអុញ....

- ហើយចុះល្បងសំណាងទៅស្គាល់នារីហ្នឹងពីកាលណា? ហេតុអីក៏ ប្រញាប់ ដណ្ដឹងអីក៏ឆក់កណ្ដៀត

រកនឹកអីមិនទាន់យ៉ាងនេះ?

- អើ! ចាស់ៗតែងពោលថា ធ្វើស្រែអោយទាន់ក្ដៅដី ចូលទៅ ដណ្ដឹងស្រីឱ្យទាន់ក្ដៅចិត្ត...

- ក្ដៅស្អី ល្បងសំណាងនោះ? ការពិតទៅ ល្បងសំណាងនោះ មាន

អារម្មណ៍ឱ្យត្រជាក់រហឹម ប៉ុន្តែអ្នកដែលក្ដៅចិត្តនោះគឺខ្ញុំឯនេះវិញទេ

ពេលគេបានការប្រពន្ធ ឯខ្ញុំបែរជាត្រូវដេកងាប់.... ពុទ្ធោអើយ....

ឃើញរាសីមុខស្អុយ នាងប្រមូលនិងនាយភោគខំលួងលោម :

- ណ្ហើយ! រាសីអើយ! កើតទុក្ខក៏ងាប់! មិនកើតទុក្ខក៏ងាប់ ដូចតែគ្នា... បើដូច្នោះ រាសីឯងទៅកើតទុក្ខធ្វើអី?

ដោយត្រូវនាយភោគនិងនាងប្រមូលបង្ខំពេក នាយរាសីក៏ផ្លាស់

សំលៀកបំពាក់ចេញដំណើរទៅជាមួយអ្នកទាំងពីរដែរ ។

នៅគេហដ្ឋានខាងស្រី...

រាសីលួចកេះនាយភោគ :

CHANBOKEO.COM

- ល្បង! ឯណាកូនកំលោះ?

- បន្តិចទៀតគេមកដល់ហើយ។

- ចុះកូនក្រមុំវិញ តើជានរណាដែរ?

- ខ្ញុំមិនស្គាល់ទេ... មិនដឹងថាគេស្គាល់គ្នាពីអង្កាល់ផង។

រំពេចនោះ សំណាងលេចធ្លោមកដល់ ក្នុងសំលៀកយ៉ាង សង្ហារ ដោយមានបុរសសង្ហារ៧ពីរបីរូបទៀតហែហមពីក្រោយផង។ លោកចាងហ្វាងនិងបុគ្គលិកភាពយន្តច្រើននាក់ក៏បានមកដល់ថែម ទៀត។ រាសីសំលឹងមើលគេទាំងអស់យ៉ាងប្រហើរ ថែមទាំងនឹក ឆ្ងល់ថា ហេតុអ្វីសំណាងគេមានវាសនាល្អម្ល៉េះ? រួចចុះហេតុអ្វីក៏ ជោគជតាវាសនារបស់នាយ បែរជាធ្លាក់ចុះទៅវិញឥចឹង?

រាសីបុកពោះភិប។.... ខ្លាចត្រូវមាត់សំណាងពីរឿងថ្ងៃមុន ប៉ុន្តែផ្ទុយពីការគិតរបស់នាយស្រលះ... កាលបើសំណាងក្រលេកឃើញ រាសី នាយភោគនិងនាងប្រមូលហើយ ស្រាប់តែគេញញឹមពព្រាយ ដាក់អ្នកទាំងបីយ៉ាងស្រស់ត្រកាល។  រាសីនឹកភ្ញាក់ផ្អើលយ៉ាងខ្លាំង ហើយនឹកគិតថា:

- មុខញញឹមខុសរឿងយ៉ាងនេះ ច្បាស់ជា.....ពុលកញ្ឆាពីម្សិលមិន ទាន់អស់ជាតិនៅឡើយទេ!

ពេលវេលាក៏បានចូលមកដល់...

ចាស់ទុំក៏អញ្ជើញកូនក្រមុំអោយចេញបង្ហាញខ្លួន។ រាសីបែរ ភ្នែកសំលឹងទៅមើលធិតា ស្រាប់តែភ្ញាក់បើកភ្នែកធំៗ វិះតែភ្លេច ដកដង្ហើមម្តងៗទៅហើយ ត្បិតនារីប្រិមប្រិយនោះមិនជានរណា ប្លែកមុខឡើយក្រៅពីនាងកញ្ញាផល្លាតែម្នាក់នោះឯង។ រាសីឃើញ នាងភ្លាមក៏លាន់មាត់ថា:

- ព្រះអើយ! ម៉ែអើយ! ឪអើយ!... បាអឹងអឺអើយ.... ហេតុអី ក៏យ៉ាងនេះទៅវិញ? យើងឯនេះខំរកមធ្យោបាយមិនអោយសំណាង រៀបការបានឡើយ ហើយចុះយ៉ាងម៉េចយ៉ាងម៉ាបានជាគេបែរជា ពេញចិត្តនឹងគ្នាយ៉ាងឆាប់រហ័សដូចផ្លេកបន្ទោរដូច្នេះទៅវិញ?តើមក ពីហេតុអីទៅ? យើងគិតមិនយល់ទេ....

រំពេចនោះ នាយភោគដែលជាមេបាខាងប្រុសក៏ស្រដីថា:

- អាហ៊ែម!... គឺថា សំណាងដែលជាកូនកំលោះដ៏សង្ហារ... មានការ ពេញចិត្តចំពោះធិតាដ៏ស្រស់ស្អាតខាងនេះ...មានបណ្ណាការប៉ុណ្ណេះ... សូមរៀបការឆាប់នេះ... តើលោកមេបាចាស់ទុំខាងស្រីយល់យ៉ាង ណាដែរបាទ...?

ចាស់ទុំខាងស្រីឆ្លើយភ្លាមៈ



-
លោកគ្រូបានទស្សន៍អោយនាងតាំងពីនៅឯស្រុក
មកម្ល៉េះថា នាង
ផល្លានឹងត្រូវបានជួបគូព្រេងជាបុរសសង្ហារ
ហើយជាតារាភាពយន្ត ផង... ឃើញថាពេលនេះ
អ្វី១ក៏ធ្វើដំណើរត្រូវគន្លងដែលលោកគ្រូ
ទស្សន៍ទុកនោះយ៉ាងឆុតឆាប់ ។ បើដូច្នេះហើយ
យើងខាងស្រីក៏មិន ប្រកែកអ្វីដែរ...
សំណាងញដូច្នោះក៏ញញឹមឡើងប៉ោងថ្ពាល់ ។
ចំណែកស្រីស្រស់
ក៏មានកិរិយារីករាយមិនខុសគ្នាពីសំណាងឡើយ ។
លុះសាមីខ្លួនទាំង
ពីរបំពាក់ចិញ្ចៀនភ្ជាប់ពាក្យចំពោះគ្នាទៅវិញទៅ
មក ស្រាប់តែរាសី លាន់មាត់យ៉ាងខ្លាំង១ថា !

- អឺ!!.... អោយវាងាប់ស្រលះសាធុអញ្ចឹងទៅចុះ!

ភ្ញៀវទាំងអស់បែរមើលមុខនាយរាសីឡើងរហង់ បើកភ្នែកធំ១ ទំនងមិនយល់ពីអ្វីដែលនាយកំពុងឧទាននោះទេ ។ គេមើលមុខគ្នា ទៅវិញទៅមកសំដែងទឹកមុខងឿងឆ្ងល់ ។

យប់នោះរាសីដេករសាប់រសល់រាស់ព្រឹក មិនដឹងថានាយគួរជឿ ហោរឬក៏មិនគួរ ។ ចំណែកសំណាងវិញ ដេកអោបរូបថតស្រីស្រស់ ញញឹមមិនដាច់ ឡើងជ្រួញមុខចង់កើតជាតាចាស់វិញទៅហើយ....

រាសីគេងគិតតែម្នាក់ឯងថា :

- បើលោកតាទាយអោយនាយសំណាងមិនឆុត... ប្រហែលជាទាយ អោយយើងមិនឆុតដែរហើយ... ប៉ុន្តែ... ម៉េចក៏លោកតាទាយ អោយបងភោគនិងប្រពន្ធគាត់នោះក៏ឆុតសំបើមម្ល៉េះ? តើគួរអោយ ជឿឬមិនគួរអោយជឿហ្ន៎?..... ហ៊ឺ!...... ពិបាកចិត្តអ្វីម្ល៉េះទេ លោកអើយ....!!! ឱ! ព្រះជាម្ចាស់អើយ... កុំអោយខ្ញុំងាប់អី... សូមមេត្តាអនុញ្ញាត្តអោយខ្ញុំរស់មានកូន៥ចៅ១០សិន សឹមទៅណា ទៅណី... ពេលនោះ ខ្ញុំលែងតវ៉ាហើយ....

CHANBOKEO.COM

00000000000

00000000

000

0

CHANBOKEO.COM

# វគ្គទី៧

## ថ្ងៃអន្យា

សំណាងគេជាមនុស្សចិត្តក្តៅណាស់ ។ តាំងពីភ្ជាប់ពាក្យកាល ណាមក នាយដេកមិនដែលលក់ទេ ស្រម័យឃើញតែថ្ងៃដែលខ្លួន រៀបការ ទៅណាមកណា ដើរញញឹមអោយជាប់... មើលមេឃ ញញឹម.... មើលដើមឈើក៏ញញឹម... មើលដំបូលផ្ទះក៏ញញឹម ខុសស្រលះពីនាយរាសីដែលឃើញតែធ្វើ មុខជូរស្អុយប៉ែដូចខ្មោច ដែលរកទីចាប់កំណើតមិនបានដូច្នោះដែរ ។

CHANBOKEO.COM

មិនយូរប៉ុន្មានថ្ងៃរៀបការរបស់សំណាង ក៏មកដល់យ៉ាងឆាប់ រហ័ស ធ្វើអោយរាសីរិតតែកើតទុក្ខខ្លាំងឡើង ។ នាយភោគជាអ្នក ជួយហៃអើនាយសំណាង ។ រីឯនាងប្រមូលជាអ្នកជួយលួងលោម នាយរាសី...    ទាំងបួនមុំហាក់ដូចជាដើរបទភ្លេងមិនស៊ីចង្វាក់គ្នាអ្វី

ទាល់តែសោះ ។

ថ្ងៃមួយ... ភ្លេងការក៏លាន់ឮឡើងខ្ទ័រកាត់ភូមិកាត់ស្រុក...

សំណាងញញឹមក្រាបក្បាលដល់ខ្នើយសំពះមេបា ទទួលចាប់ដៃ នារីរូបស្អាតឈ្មោះផល្លាជាគូគ្រង ។ ពេលនោះនាយនឹកក្នុងចិត្តថា:

- ឃើញទេ... លោកតាអើយ... ទាយអោយខ្ញុំមិនផុតសោះ ឡើយ...ពេលនេះ ខ្ញុំកំពុងតែរៀបការជាមួយនារីដ៏ស្រស់ស្អាតមួយ រូបដែលមិនមែនជានាងក្រមុំរែកពោតស្ងោរលក់ដូចលោកតាទស្សន៍ទុកអោយខ្ញុំនោះឡើយ.....

ពិធីក៏មានដំណើរទៅយ៉ាងអឺកធឹកក្រៃលែង ។

នៅរាត្រីផ្សំដំណេករបស់សំណាងនិងនាងផល្លា....

រាសីនៅដេកបន្ទប់ម្ខាង រៀបគ្រែរៀបខ្នើយហើយ ក៏ស្លៀកពាក់ យ៉ាងស្អាត ឡើងទៅដេកលើគ្រែរង់ចាំម៉ោងងាប់.... ។ នាយដេក គងថ្វាសបណ្ដើរ បន់ព្រះបណ្ដើរ យំបណ្ដើរ...

- ឱ! ព្រះអើយ! ហេតុអីជោគជតារបស់ខ្ញុំចុះត្រដាបខ្លាំងម្ល៉េះ? ថ្ងៃនេះជាថ្ងៃដែលគេរាល់គ្នាផឹកយ៉ាងសប្បាយ ចុះហេតុអីក៏ព្រះអង្គ ដាក់ទោសអោយខ្ញុំងាប់ខានផឹកទៅវិញ? អនិច្ចាណាស់! អ្នកដែលមានបាបគួរណាស់តែជាព្រះព្រហ្មវិញទើបសម ព្រោះអីលោកមក ចារលិខិតធ្វើបាបកូនចាប អោយខានផឹក ខានសប្បាយអស់.....

នៅបន្ទប់ម្ខាងទៀត នាយភោគកំពុងតែជជែកជាមួយប្រពន្ធ :

- អូនប្រមូលហ្អាំស!

- ចាំស!

- តើអូនគិតថាលោកតាហោរនៅបាត់ដំបងនោះទាយឆុតឬទេហ៎?

- ខ្ញុំថាពិតជាឆុតណាស់ មើលតែយើងទាំងពីរចុះ បានទទួលលាភ ដូចលោកតាទាយឥតខុសម៉ាម៉ាត់ទេ ។

- បើដូច្នោះមែន ហេតុអ្វីក៏សំណាង មិនបានរៀបការជាមួយ នាងលក់ពោតស្ងោរ តែបែរជាមកជួបគូព្រេងដែលជានារីរូបស្រស់ សោភាហើយជាតារាភាពយន្ដទៅវិញ?

- មិនដឹងដែរល្បងអើយ... តែបើលោកតាទាយមិនឆុតវិញនោះ ក៏ល្អដែរ... ខ្ញុំអាណិតប្អូនរាសីណាស់... មិនចង់អោយគេស្លាប់ទាំង នៅក្មេងតចឹងទេ ។

- មែនហើយ... មើលគ្នាចុះ... ដេកភ័យងាប់មុនស្លាប់យូរខែមក ហើយ... ឃើញដូចជាពិបាកភ្នែកណាស់... សូវ....បាំងព្រួស! ងាប់តែម្ដង ដូចជាប្រសើរជាងដឹងមុន...

- យី! ល្បងឯងមាត់មិនល្អសោះ ។ ម៉ោះ!ទៅរកមើលរាសីបន្តិច មើល៍ ថាតើគេយ៉ាងណាដែរហើយ?...

ទាំងពីរនាក់ក៏ដើរចេញទៅ សំដៅបន្ទប់របស់រាសី....

និយាយពីសំណាងម្ដង...

នៅក្នុងបន្ទប់ សំណាងអង្គុយនិយាយសាសងជាមួយភរិយា ដ៏ស្រស់ស្អាតរបស់ខ្លួន :

- ផល្លា!

- ចាំស បង!

- អូនដឹងទេហ៎ ថាបងស្រលាញ់អូនណាស់!

- មែនហ្អែសបង?

CHANBOKEO.COM
CHANBOKEO.COM

- មែនណា៎...

- កុំថាតែមាត់....

- បងសូមស្បថជូនអូន!

- អញ្ចឹង បងប្រាប់អូនសិនមក៏ ថា ហេតុអ្វីបានជាបងបេតីរូប អូនដល់ម្លឹង?

- មិនដឹងទេហ៎...... គ្រាន់តែដឹងថា បងបាក់ចិត្តស្រលាញ់អូនតាំងពី បានជួបអូននៅថ្ងៃដំបូងម្លេះ?

- តើថ្ងៃណាទៅជាថ្ងៃដំបូងនោះ....?

- គឺ... ថ្ងៃដែលលោកសេដ្ឋាណែនាំរូបអូនអោយបងស្គាល់នោះអី... ហេតុតែគូព្រេង គ្រាន់តែយល់ភក្ត្រភ្លាមស្រលាញ់ភ្លែតរៀបការ ភ្លិបតែម្តង។

- តើបងជាក់ច្បាស់ក្នុងចិត្តហើយថា អូនជានារីដែលបងពេញចិត្ត បំផុត?

- ពិតណាស់អូន!

- មិនអោយបងដូរចិត្តទេហ៎ណា៎

- បងមិនដូរទេ... ទោះបីមេឃរលំភ្នំរលាយក៏ដោយ... ក៏ចិត្តបងមិន ផ្លាស់ប្តូរដែរ បងសូមសច្ចា។

- ចា៎ស១ អូនជឿបងហើយណា៎ប្តីសំលាញ់។

- ហើយចុះអូនវិញ តើអូនមានលួចពេញចិត្តរូបបងខ្លះទេហ៎?

- អត់ទេហ៎...

- ហ្អា៎ស? ម៉េចអញ្ចឹង?

- អូនថាលេងទេ... ការពិតអូនក៏ពេញចិត្តរូបបងដែរ ជាពិសេស ទៅទៀតនោះ គឺ...

- គឺយ៉ាងម៉េចទៅអូន?

- គឺ... ខ្ញុំមិនចង់រៀបការអ្នកក្រីក្រនៅជនបទទេ... ខ្ញុំចង់មាន គ្រួសារជាបុរសទីក្រុង សង្ហារហើយមានកេរ្តិ៍ឈ្មោះល្បីទៀតផង.... អោយសមដូចពាក្យដែលលោកតាហោរទាយនៅបាត់ដំបងឥចឹង...

- អូហ៎! អូនជាអ្នកស្រុកបាត់ដំបងដែរ?

- ចា៎ស! មែនហើយ!

- ហើយអូនអោយលោកតានៅផ្សារណាត់ទាយអោយ...

- ចា៎ស! ហើយចុះម៉េចក៏បងស្គាល់ដែរ?

CHANBOKEO.COM

- បងក៏ជាអ្នកបាត់ដំបងដែរតែបងមិនជឿលោកតាហោរហ្នឹងទេ... ព្រោះគាត់ធ្លាប់ទាយអោយបង គ្មានត្រូវអីបន្តិចសោះ...

- តែគាត់ទាយអោយអូនវិញ ឆុតឆាប់ឥតខុសម៉ាម៉ាត់ឡើយ ។ រួចចុះ លោកតាទស្សន៍អោយបងថាម៉េចខ្លះទៅ?

- ណ្ហើយ! ចាំថ្ងៃក្រោយបងនិយាយប្រាប់អូនចុះ... តែពេលនេះ បងងងុយគេងហើយ... ម៉ោះចូលគេង ។

- ចាស! បងសំរាន្តមុនទៅ... ចាំអូនសិតសក់ហើយ អូននឹង ចូលគេងតាមក្រោយ ។



នាងផល្លាក៏ស្រវាទាញក្រាស មកសិតសក់ដ៏ខ្មៅរលើបវែង អន្លាយរបស់នាង ។ រីឯសំណាងលួចសំលឹងប្រពន្ធពីក្រោយទាំង ញញឹម ។ មួយស្របក់មក នាយក៏ស្ទុះងើបទៅឈរពីក្រោយនាង ផល្លា ដែលកំពុងអង្គុយសិតសក់នៅមុខកញ្ចក់...

- ម៉ោះ អោយបងសុំសិតសក់អោយអូនបានទេ?

តាមប្រពៃណីចិន បុរាណ បុរសជាស្វាមីត្រូវសិតសក់អោយប្រពន្ធ ពេលរាត្រីផ្សំដំណេក ទើបជីវិតគ្រួសារបានស្ថិតស្ថេររហូតរៀងទៅ ។ ប៉ុន្តែតាម ប្រពៃណីខ្មែរយើងវិញ បុរសដែលស្រលាញ់ភរិយាបំផុតច្រើន សំដែងនូវសេចក្តីស្រលាញ់ដោយការសិតសក់អោយភរិយា... គឺគេ សិតសក់នាងដោយបញ្ចូលអារម្មណ៍របស់គេតាមរយៈធ្មេញស្និតទៅ ក្នុងជើងសក់របស់នារីនោះទើបអារម្មណ៍ទាំងពីរនាក់ទាក់ទងគ្នា ទៅវិញទៅមក ហើយយល់ចិត្តគ្នាជាក់ច្បាស់ ដោយមិនបាច់ប្រើ

ភាសានិយាយរៀបរាប់អ្វីច្រើនទៀតទេ។ នោះហើយជាសុភមង្គល ដ៏រុងរឿងមួយក្នុងគ្រួសារ ដែលគេមិនអាចបំភ្លេចគ្នាបានរហូតចាស់ ស្លាប់រៀងខ្លួន។

ឮសំណាងរៀបរាប់ដូច្នោះ នាងផល្លាញញឹមឡើង ហើយក៏ហុច ក្រាសសិតសក់ទៅអោយបុរសជាប្តីសិតអោយនាងភ្លាម។ សំណាង ទទួលយកហើយ ក៏ដាក់ស្និតអូសបន្ថើរលើកេសាដ៏ខ្មៅរលើបរបស់ ភរិយា។ ភ្លាមនោះ នាយក៏លួចអោនថើបសក់នាង រួចក៏សិតបន្ត ទៅទៀត ស្រាប់តែនាយយើងភ្ញាក់បើកភ្នែកធំៗ ស្ទុះយកក្រាស មកញែកសក់នាងមើលជាថ្មីម្តងទៀត យ៉ាងពិនិត្យពិច័យ ហើយក៏ ស្រដីលាន់មាត់ថាៈ

- ផល្លា! ហេតុអ្វីក៏ក្បាលរបស់អូន មានស្នាមទំពែករលោងមួយដុំ អញ្ចឹង?

- ចាស! គឺ...

- អូនកើតអំបៅអំបែកកាលនៅពីក្មេងមែនទេហ៎?

- ចាស! អត់ទេ! ការពិតទើបតែទំពែក កាលពីប៉ុន្មានខែមុនពេល ខ្ញុំមកភ្នំពេញនេះ ដើម្បីប្រលងចូលកម្មវិធីស្រីស្រស់ប្រុសស្អាតនោះ ទេតើហ៎។

- អូហ៎អញ្ចឹង? ហើយចុះអូនមានរឿងហេតុអ្វីទៅ បានជាមានរបួស ដល់ទៅទំពែកលលាដ៏ល្វែងដុះសក់យ៉ាងនេះ?

- ហ៊ឹ! អោយតែនឹកដល់រឿងនេះកាលណា អូននៅតែនឹកខឹងនឹង រឿងហេតុនោះ មិនទាន់ត្រជាក់ចិត្តវិញទេណា៎បង...

- មានរឿងធំដល់ម្លឹងផងឬអូន?

- ចាស! មែនហើយ! កាលដើមឡើយ អូនធ្លាប់រែកពោតស្ងោរ លក់នៅផ្សារណាត់បាត់ដំបង....

- ហ្អាស? ថាម៉េច? អូនធ្លាប់លក់ពោតស្ងោរនៅបាត់ដំបង?

- ចាស បង! ចង្រៃថៃដន្យអី នៅព្រលប់មួយ មើលមុខមិនច្បាស់ មានបុរសម្នាក់ស្រវឹងមកពីណាមិនដឹង បានយកដុំថ្មគប់ត្រូវចំក្បាល របស់អូនបែកឈាមឆុរហើយនាយក៏រត់បាត់ទៅ។ កាលនោះ មាន បុរសស្ត្រីច្រើននាក់កំពុងចោមរោមមើលហោរ.... ខ្ញុំខ្មាស់គេពេក ទើបគេចខ្លួនមក ដោយមិនទាំងបានដឹងថា អ្នកគប់ដុំថ្មនោះមាន មុខមាត់យ៉ាងណាផង...

- ពុទ្ធោ! ធម្មោ! សង្ឃោ! ផឹកអស់ប្រេងខ្យល់ម៉ាឡូ ក៏មិនបាត់ ខ្យល់គដែរខ្ញុំអើយ.....

សំណាងប្រាសខ្លួនដួលភីងលើគ្រែ ខ្យល់គនិយាយលេងចេញ តែម្តង...

ចំណែកនាងផល្លាក៏អង្គុយមើលទៅប្តីធ្វើមុខឡឹងឡង់ៗ។

CHANBOKEO.COM

និយាយពីរាសីវិញម្តង......

នៅលើគ្រែគេងក្នុងបន្ទប់ រាសីដេកភ័យបែកញើសស្រោក់ៈ

- ណាំង៉ូវត្រសក់ ភ្ញាក់គ្រវាត់តោ អារ៉ាហាត់តោ ក្រមាសំពត់ ដេរប៉ាក់...!!!

រាសីដេកសូត្រធមិតែម្នាក់ឯង រង់ចាំអោយដល់ម៉ោងងាប់ ស្រាប់តែ...

- នែ៎ នាយរាសី! ឯងដេកទន្ទេញស្អីគេហ្នឹង?

- អូហ៎ល្បងភោគទេហ៎? គឺខ្ញុំកំពុងដេកសំពះសូត្រធមិថ្វាយបង្គំព្រះ រង់ចាំពេលា....

- ហើយសូត្រធមិស្អី ឮសួរតែដេរប៉ាក់ៗ ឥចឹង?

- មិនដឹងទេ ល្បងអើយ! ខ្ញុំធ្លាប់តែឮគេចាក់មេក្រូពេលលោកសង្ឃ សម្មាទានសីល...

ក៏ចេះតែទន្ទេញៗលេងៗតាមរហូតចាំមាត់ អោយ រ៉ិលអញ្ចឹងទៅ។

- ហើយមានដែលអានអក្សរទេថា ធមិព្រះហ្នឹងគេសរសេរយ៉ាង ម៉េច អានយ៉ាងម៉េចនោះ?

- យី!... អោយអានយ៉ាងម៉េច បើខ្ញុំមិនដែលចូលសាលារៀនអក្សរ ម៉ាអង្គ ផង?

- អញ្ចឹងតើហ៎ បានជានាយសូត្រធមិប៉ែឡាំដូចចិនហៃណាំរៀន និយាយខ្មែរ....

- សូត្រច្បាស់ប៉ុណ្ណឹងហើយថាមិនច្បាស់ទៀត... យ៉ាប់មែនល្បងឯង សង្ស័យតែតូវការកង្វារខ្វារត្រចៀកហើយ។

ប៊ុង! ប៊ុង! ប៊ុង!

នាឡិកាប៉ោលនៅលើជញ្ជាំងគោះម៉ឺងៗ ជាសញ្ញាថាជាម៉ោង ១១កន្លះយប់ហើយ។ រាសីកាន់តែភ័យឡើងៗ...

- ល្បងភោគ... ជិតដល់ម៉ោងខ្ញុំស្លាប់ហើយ...

- អឺ! យើងដឹងហើយ...

- បងប្រមូល...

- ចាំស!

- ពេលប្អូនស្លាប់ទៅ... សូមមេត្តាកុំយកខ្មោចខ្ញុំទៅដុតអី?

- អូហ៎ ហើយចុះព្រោះអ្វីទៅ?

- ព្រោះខ្ញុំខ្លាចត្រូវភ្លើងក្តៅរលាកសាច់ណាស់...

- អញ្ចឹង... ចាំបងយកសពឯងទៅកប់ចុះ...（នាយភោគបន្ថែម）

- អត់ទេ... កប់ផ្តេក... ត្រូវដីសង្កត់... ថប់ដង្ហើមតឹងទ្រូង ពិតជា ពិបាកទ្រាំណាស់....

- ឥចឹងចាំបងកប់ឯងឈរ...

CHANBOKEO.COM
CHANBOKEO.COM

- អីយ៉ូយ... ខ្ញុំច្បាស់ជាឈររោយជង្គង់ស្លាប់ហើយ...

- អីយ៉ា... អញ្ចឹងយើងត្រូវធ្វើម៉េចទៅ ហ្អាស? (នាយភោគសួរ)

- ខ្ញុំថា មានតែបណ្តែតទឹកហើយ.... (នាងប្រមូលអោយយោបល់)

- អត់ទេ... ខ្ញុំខ្លាចហូរតាមទឹកចូលដល់ស្រុកគេ លែងបានមកចាប់ កំណើតស្រុកខ្លួនឯងវិញ។

- អញ្ចឹងអោយបងធ្វើយ៉ាងម៉េច...?

- មើលទៅ... សូមពឹងបងអោយដាក់សពខ្ញុំក្រោមដើមឈើខាង មុខផ្ទះបងហើយ...

មួប់ត្រជាក់ហើយមានអាកាសរហើយស្រួលផង

- អ៊ុញមើលគេ... យឺ... ជិតងាប់ហើយ នៅឆ្លៀតរើសកន្លែងដេក ងាប់នោះទៀតអ៊ី.... (នាយភោគលាន់មាត់)

- ល្បងភោគ... (រាសីហៅ)

CHANBOKEO.COM

- អឺ...

- ខ្ញុំឈឺពោះណាស់ ទ្រាំមិនបានទេ...

- បើឈឺម៉េចក៏មិនទៅបង្គន់...?

- ទៅម៉េចកើត បើជិតដល់ម៉ោងងាប់ហើយហ្នឹង?

- យីអើ!... ទៅបន្ទូរតរិយាបថសិនទៅ ចាំមកបន្តសាច់រឿងដេក ងាប់តទៅទៀត ឮហើយនៅ?

- អញ្ចឹង ខ្ញុំទៅសិនហើយ

- អឺ!

រាសីក្រោកដើរអោបពោះចូលបង្គន់ យ៉ាងយូរ...

- រាសី...

- ប៉ាទ!

- អីក៏យូរម្លេះ?...

- ឈឺពោះណាស់ល្បងអើយ.... ចាំបន្តិចទៀត ពេលខ្ញុំហៅបង... ចាំមក ជួយគ្រាហ៍ខ្ញុំយកទៅដេកចាំស្លាប់វិញ....

មួយស្របក់ក្រោយមក...

- រាសី?

- បាទ!

រាសីបើកទ្វារចេញមក ធ្វើមុខស្លេក...

CHANBOKEO.COM

- ខ្ញុំជិតងាប់ហើយ... មែនទេល្បងភោគ បងប្រមូល?

- អឺ... គឺ... ថា.... ឯងមានមុខស្លេកមិនខុសពីខ្មោចងាប់មែនទែន នោះទេ

- ខ្ញុំជិតងាប់ហើយ.... មិនប៉ុន្មាននាទីទៀតទេ.. ដល់ម៉ោង១២ពាក់ អាធ្រាតហើយ... ហើយខ្ញុំក៏នឹងងាប់អស់ជីវិតដែរ...

- ឯងងាប់ឆ្កួតយកំ ស្អីនាយរាសី...? មើលហ្ន៎...!

- ប៉ាទ? ល្បងភោគមានប្រសាសន៍ថាម៉េច?

- រាសីឯងមើលនាឡិកាមើស៍! ឥលូវម៉ោងវាដើរហួសដល់ទៅ១៥ នាទីក្រោយពេលអាធ្រាតទៅហើយ... ហើយឯងក៏មិនទាន់ងាប់ ដែរ បើដូច្នេះឯងច្បាស់ជាលែងងាប់ហើយណា៎?

- មែនហ្អែសល្បង... ?

- អឺ! គ្នាថា.. មែនហើយ!!

- ជយោ! រាសីខ្ញុំលែងងាប់ហើយ... ជយោ!!

0000000000

000

CHANBOKEO.COM
CHANBOKEO.COM

## វគ្គទី៩

## ជាន់កែងហោរា

CHANBOKEO.COM

នាយភោគនាំគ្នីគ្នាទាំងហ្វូងធ្វើដំណើរទៅក្រុងបាត់ដំបង ដើម្បី ទៅជួបលោកតាហោរា។ មកដល់ផ្សារណាត់លោកតាឃើងនៅតាំង រានទាយហោរ នៅកន្លែងដដែលម៉ោងដដែលរាល់ថ្ងៃ។

- ជំរាបសួរលោកតា! ខ្ញុំឈ្មោះភោគ ប្រពន្ធឈ្មោះប្រមូល... មកថ្វាយបង្គំជូនកំណល់គ្រូ ដែលលោកទាយអោយខ្ញុំនិងប្រពន្ធ យ៉ាងឆុតបំផុត រហូតបានធ្វើអ្នកមានដូចការទស្សន៍ទាយនោះមែន។

លោកតាញញឹមទទួលយកកំណល់ទាំងទឹកមុខញញឹមពព្រាយ :

- អើ! ចេះនឹកដល់មនុស្សចាស់ ផ្ញើតវាន់បន្តិចបន្តួចដូច្នេះពិតជាបាន បុណ្យ ច្រើនណាស់... កុំភ្លេចណ៎.... ពេលចៅមានបានហើយ កុំភ្លេច

ធ្វើបុណ្យចែកទានដល់អ្នកក្រីក្រផង សូមអោយអ្នកទាំងពីរមាន សំណាងរហូតរៀងទៅ។

នាយភោគនិងភរិយាអោនសំពះលោកតាហើយ ក៏ក្រោកថយ ចេញទៅវិញ។

នាយសំណាងនិងនាងផល្លា ក៏មកក្រាបសំពះលោកគ្រូម្តង។

- លោកតាអើយ..! ចៅសូមទោស.. ដែលចៅបានប្រមាថលោកតា ឥលូវចៅបានជួបគូព្រេងដែលលោកតាទាយទុកនោះហើយ... ពិត ជាត្រឹមត្រូវអស្ចារ្យណាស់! ថ្ងៃនេះចៅសូមយកកំណល់គ្រូមកថ្វាយ

- អើ! ល្អៗ! អរគុណណាស់ចៅតាអើយ។ តាសូមជូនពរអោយចៅ ឯងចាប់ដៃគ្នាជាគូមានសុភមង្គលតរៀងទៅ។

សំណាងនិងប្រពន្ធ ក៏ផ្គុំដៃអោនសំពះទទួលពរពីលោកតាហើយ ក៏ថយទៅវិញ។ នៅសល់នាយរាសីចុងក្រោយគេ។ លោកតាឃើញ នាយហើយក៏សួរថា :

- ហើយចុះចៅជីឯង មានអ្វីផ្ញើតាដែរទេ?

- ហៃសៗ! លោកតាទាយអោយខ្ញុំមិនផុតដូចគេឯងសោះ ធ្វើឱ្យខ្ញុំ ដេកភ័យរាប់ខែរាប់ថ្ងៃមកហើយ ខាតអាយុអស់... ដូច្នេះលោកតា ត្រូវតែសងជំងឺចិត្តខ្ញុំវិញទើបត្រឹមត្រូវ....

- អូហ៎? លោកតារកស៊ីទស្សន៍ទាយម៉ាអាយ៉ូសទៅហើយ មិនដែល ទាយខុសម្តងណាទេណ៎ាចៅជីអើយ ។

- តែលើកនេះ ខុសជាលើកដំបូងហើយ លោកតា!

- អញ្ចឹង កាលណោះ តាទាយអោយឯងថាម៉េចខ្លះ?

- គឺទាយថា ខ្ញុំនេះនឹងដេកងាប់នៅពាក់អាធ្រាត នៅរាត្រីដែលមិត្ត របស់ខ្ញុំខាងនេះគេផ្សំដំណេក...

- ហើយចុះឯងមានទៅដេកងាប់ទេ?

- បាទ! ទៅដេកហើយ... តែអត់ងាប់ផង...

- អូហ៎ មិនមែនទេលោកតា! (នាយភោគឆ្លើយកាត់) ការពិត កាលណោះ នៅម៉ោង១២យប់នោះ នាយរាសីមិនបានដេកងាប់ទេ... គឺនាយកំពុងតែអង្គុយសំងំដោះទុក្ខសត្វនៅក្នុងបន្ទប់ទឹកឯណោះ

- អូហ៎ មកពីអញ្ចឹងតើហ៎... (លោកតាលាន់មាត់)

- យ៉ាងម៉េចទៅលោកតា? (រាសីសួរ)

- យើងទាយថាឯងត្រូវដេកងាប់ តែឯងបែរមិនព្រមដេក ចៅជី ឯងបែរជាទៅអង្គុយបន្ទោរបង់ទៅវិញ... ដឹងទេហ៎ កាលណាចៅ ឯងធ្វើយ៉ាងនេះ វាធ្វើឱ្យសាបឥទ្ធិពលគ្រូអស់រលីងណ៎ា...? ពុទ្ធោ!!! អញ្ចឹងតើហ៎ បានសព្វថ្ងៃនេះ តារកស៊ីលែងបានអស់អាលីង...!!

- ហែស់ៗ! សូមទោសលោកតា... អញ្ចឹងរួចគ្នាចុះណ៎ាបាទ! (រាសីសើចរអឹក) ហែ់សៗ!

- ហ៎ាស់ៗហ៎ា (នាយភោគសើចតាម)

- ហ៊ូៗ ហូ!! (សំណាងសើចដែរ)

- ហេវ! ហេវ! ហេវ! (លោកតាមានប្រសាសន៍)

- ហើយ! ហើយ! ហើយ! ឯវិ!! (នាងប្រមូលបន្ថែម)

នៅភ្នំពេញ...

រាសីទិញឥវ៉ាន់ប្រើប្រាស់មួយកំប្រោង យកទៅធ្វើជូនចាស់នៅឯ វត្តដើម្បីទៅជំរាបសួរសុខទុក្ខ ។

- ចៅឯងមុខមាត់ស្រស់បស់ណាស់ឥលូវ... ប្រហែលរាសីឡើងវិញ ហើយ ។

CHANBOKEO.COM
CHANBOKEO.COM

- បាទយាយ! ខ្ញុំសង្ឃឹមថាអញ្ចឹងចុះ។ នេះ ខ្ញុំមកលេងយាយ ហើយមានផ្ញើឥវ៉ាន់បន្តិចបន្តួចជូនយាយទុកប្រើប្រាស់បាទ។

- អឺ! ចៅឯងមានចិត្តមានថ្លើមណាស់។ សូមអោយចៅអាយុវែង!!

មួយស្របក់ក្រោយមក រាសីក៏សំពះលាដូនចាស់ ត្រលប់មកផ្ទះវិញដោយអារម្មណ៍សប្បាយរីករាយលើសពេលណាៗទាំងអស់ ក្នុងជីវិតរបស់គេ។

# ចប់

CHANBOKEO.COM
CHANBOKEO.COM